## មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ខាត់ សឿន ភេទស្រី អាយុ៥៧ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ "កងចល័ត"**

**ស្រុកកំណើតនៅភូមិពាម ឃុំព្រៃពួច ស្រុកអង្គរស្នួល ខេត្តកណ្តាល**

**រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ម៉ឹម សុវណ្ណ**

**០១:៣៩:២៣**

**៥០ទំព័រ**

សុវណ្ណៈ អ៊ំជាជីបូនខ្ញុំសូមជំរាបសួរ ។

សឿនៈ ចាស ។

សុវណ្ណៈ ខ្ញុំសូមណែនាំខ្លួនខ្ញុំឲ្យស្គាល់ខ្ញុំឈ្មោះ ម៉ឹម សុវណ្ណ ។

សឿនៈ ចាស ។

សុវណ្ណៈ ខ្ញុំជាបុគ្គលិករបស់អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមកថ្ងៃនេះខ្ញុំសូមជួបសម្ភាស អ៊ំ ពូមីងមួយចំនួនគាត់ធ្លាប់រស់នៅតំបន់នេះ ពីមុនមកនៅក្នុងស្រុកត្រពាំងប្រាសាទនេះអ៊ំ ណាស់ ហើយថ្ងៃនេះថ្ងៃទី១៩ខែ១២ឆ្នាំ២០១៣ ចឹងខ្ញុំចង់ឲ្យអ៊ំណែនាំខ្លួនថា អ៊ំឈ្មោះអី គេដែរ?

សឿនៈ ខ្ញុំឈ្មោះ ខាត់ សឿន ។

សុវណ្ណៈ អ៊ំអាយុប៉ុន្មានហើយ?

សឿនៈ ខ្ញុំអាយុ៥៧ហើយ ។

សុវណ្ណៈ អ៊ំមានចាំថា អ៊ំកើតឆ្នាំណា?

សឿនៈ ខ្ញុំកើតឆ្នាំ១៩៥៧ ។

សុវណ្ណៈ អ៊ំមានមុខរបរធ្វើអីគេ?

សឿនៈ ខ្ញុំធ្វើស្រែក្ដួយអើយ ធ្វើចម្ការបន្តិចបន្តិច ។

សុវណ្ណៈ អ៊ំជាកសិករ?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងអ៊ំភាគច្រើនធ្វើស្រែឬធ្វើចម្ការ?

សឿនៈ កាលពីមុនមកធ្វើចម្ការមានអីភ្លួរឥឡូវហ្នឹង ធ្វើស្រែខ្លះធ្វើចម្ការខ្លះ មានដំណាំបន្តិចបន្តួចដាំ សណ្តែកដាំ ដាំពោត ដាំអីហូបទៅបានច្រើនក៏លក់ខ្លះទៅ មានដាំដំឡូងដាំអីទេ ខ្ញុំដាំដំឡូង

បានបន្តិចដែរ ទើបដាំឆ្នាំនេះ ដីខ្ញុំរាំងទឹកវាមិនសូវល្អ ចឹងដាំដំឡូងដែរ ដាំបានកន្ទះហាត់ដែរ ហ្នឹង ។

សុវណ្ណៈ ចឹងដាំដំឡូងដាំសណ្តែកអី?

សឿនៈ ចាស!ដាំសណ្តែកដី បានហូបខ្វះលក់ខ្វះទៅណាស់ ប៉ះកើតបានច្រើនទៅ បើមិនកើតបាន បួនដប់ម្ភៃម៉ឺនចឹងទៅ ។

សុវណ្ណៈ ហើយគ្រួសារអ៊ីឈ្មោះអីគេ?

សឿនៈ ឈ្មោះ កុយ ស្រួយ ។

សុវណ្ណៈ គាត់សព្វថ្ងៃធ្វើអីដែលអ៊ី?

សឿនៈ គាត់នៅផ្ទះដែរ កាលមុនគាត់ធ្វើទាហានអីឥឡូវគាត់ចាស់ហើយ ។

សុវណ្ណៈ អតីតទាហានខាងខ្មែរក្រហម?

សឿនៈ ធ្វើទាហានយើងហ្នឹង កាលពីមុនបានទាហានខ្មែរក្រហម ឥធ្វើទាហានយើងហ្នឹងឥឡូវគាត់ ចាស់គេរំសាយគាត់ ។

សុវណ្ណៈ គាត់ជាទាហានកងពលណាអ៊ីមានចាំបានទេ របស់ខ្មែរក្រហមកាលនៅគស្វ៊ូ?

សឿនៈ កងពលតា០៥ហ្នឹង កងពល៨០១ ឥឡូវចូលនិវត្តហើយ ។

សុវណ្ណៈ គាត់អាយុប៉ុន្មានហើយ?

សឿនៈ គាត់បងខ្ញុំមួយឆ្នាំ?

សុវណ្ណៈ ចឹង៥៨?

សឿនៈ ចាស! គេកាត់ប៉ុន្មានឆ្នាំហើយ គាត់ចាស់ខស្សរាប់ឈឺផង ។

សុវណ្ណៈ ឥឡូវគាត់ធ្វើអីគេ?

សឿនៈ ឥឡូវគាត់មានធ្វើអីនៅតែផ្ទះ មើលតែគោ ស្រែគាត់មិនដែលបានទៅផង ។

សុវណ្ណៈ ចឹងគាត់រាល់ថ្ងៃជាយោធាចូលនិវត្ត?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងអ៊ីមានកូនប៉ុន្មាននាក់?

សឿនៈ មាន៦នាក់ ។

សុវណ្ណៈ ចឹងមានកូន៦នាក់?

សឿនៈ ចាស ។

សុវណ្ណៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

សឿនៈ ស្រី៣ប្រុស៣ ។

សុវណ្ណៈ ហើយសព្វថ្ងៃមានគ្រួសារអស់ហើយនៅ?
សឿនៈ នៅសល់ពីរនៅសល់ស្រីមួយប្រុសមួយដែរ តែអាមីមួយស្រីការខែមួយហ្នឹងហើយសល់ប្រុសមួយ ។
សុវណ្ណៈ ចឹងកូនពៅកូនប្រុសឬមួយកូនស្រី?
សឿនៈ កូនស្រី ។
សុវណ្ណៈ ចឹងនេះហ្នឹង?
សឿនៈ ចាស ។
សុវណ្ណៈ ចឹងជិតហើយ?
សឿនៈ ជិតការ ។
សុវណ្ណៈ ការខែណា?
សឿនៈ ការខែ១ ។
សុវណ្ណៈ ហើយកូនប្រសារធ្វើអីគេ?
សឿនៈ នៅហ្នឹងដែលហ្នឹងប្រុស វាឈ្មោះ ដារា តែហៅឈ្មោះ អាប្រុសៗ ។
សុវណ្ណៈ ធ្វើអីគេ?
សឿនៈ ធ្វើស្រែចម្ការដែលហ្នឹង ។
សុវណ្ណៈ ចឹងនៅរៀនឬមួយឈប់រៀនហើយកូនស្រី?
សឿនៈ ឈប់ហើយនេះនោះ ។
សុវណ្ណៈ ឈប់រៀនថ្នាក់ទីប៉ុន្មាន?
សឿនៈ ឈប់រៀនត្រឹមថ្នាក់ទី៦នេះហ្នឹងមានបានទៅនេះផង កាលហ្នឹងឪពុកវាឈឺទៅដល់ភ្នំពេញទៅដល់ខេត្តសៀមរាបឥវ៉ាន់នោះ អស់រាប់ពាន់ក៏វាឈប់ទៅៗ ។
សុវណ្ណៈ យ៉ាងម៉េចបានជាកូនឈប់រៀន អត់មានសាលារៀនឬក៏?
សឿនៈ មានតែវាមិនទៅវាខ្ជិល គ្មានពីណានៅផ្ទះផង ខ្ញុំទៅឪពុកវាឈឺនោះ ខ្ញុំទៅពេទ្យកូនខ្ញុំអាបងនោះវាទៅអត់ឈាមនោះគេឲ្យយកឈាមទៅដាក់បងៗវាទៅពីរនាក់ ប្អូនគាត់គេទៅភ្នំពេញខ្ញុំទៅនៅភ្នំពេញអីខ្ញុំនៅយូរដែលហ្នឹង មួយខែឬពីរខែមួយនេះវាឈប់ទៅសាលាទៅ ខ្ញុំមកវាមិនទៅវិញ វាថាខ្ជិលណាស់ឈប់យូរហើយ ។
សុវណ្ណៈ ចឹងកូនម្នាក់ទៀតថានៅលីវដែលនោះ?
សឿនៈ កូនប្រុស ។
សុវណ្ណៈ បន្ទាប់ពីម្នាក់ស្រីនេះ?

សឿនៈ ចាស ។

សុវណ្ណៈ នៅរៀនឬឈប់រៀនហើយ?

សឿនៈ ឈប់ហើយ រៀនចប់ថ្នាក់ទី៩ ធ្វើស្រែចម្ការជាមួយខ្ញុំដែលហ្នឹង ។

សុវណ្ណៈ ម៉េចបានជាមិនទៅរៀនតទៀត ម៉េចបានជាឈប់ទី៩?

សឿនៈ សាលាកាលនោះនៅត្រពាំងប្រាសាទ អត់មានអីជិះទៅ យើងមិនសូវមានលុយដែរ ។

សុវណ្ណៈ កាលហ្នឹងមានវិទ្យាល័យហើយនៅត្រពាំងប្រាសាទ?

សឿនៈ ត្រពាំងប្រាសាទមានហើយតើ ត្រឹមថ្នាក់ទី១០អី ។

សុវណ្ណៈ ម៉េចមិនឲ្យទៅរៀនបញ្ចប់វិទ្យាល័យ?

សឿនៈ ខ្ជិលជិះកង់ទៅឆ្ងាយមិនមានគ្នានផង គេអត់មានពីណាទៅអត់មានគ្នាខ្ជិលទៅ ។

សុវណ្ណៈ ចឹងពីហ្នឹងទៅត្រពាំងប្រាសាទឆ្ងាយកាលហ្នឹង?

សឿនៈ កាលហ្នឹងឆ្ងាយដែលកាលហ្នឹងយើងមិនទាន់មានម៉ូតូមានអី មានតែកង់វាខ្ជិលធាក់ទៅមក ។

សុវណ្ណៈ ប៉ុន្មាន គីឡូប្រហែលពីហ្នឹងទៅ?

សឿនៈ ដឹងប៉ុន្មានទេ កាលហ្នឹងប្រហែលជា១៥ដឹងឬ២០ឪវាចំណាំនិយាយដែរ ។

សុវណ្ណៈ កាលអត់មានជីវភាពខ្វះខាតអីទេ?

សឿនៈ កាលហ្នឹងវាខ្វះខាតដែរ ក្មួយវាអត់មានលុយកាក់ ខ្ញុំថាដឹងរៀនដល់ណាទេ ខ្ញុំថាឈប់ទៅកូន
រៀនទៅដល់ណាមិនបានធ្វើអីទេ យើងគ្មានអីផង ។

សុវណ្ណៈ ចឹងពេលដែលអ៊ំឲ្យកូនទៅរៀនពេលដែលនៅក្មេងៗ ទៅរៀនកាលហ្នឹងចង់ឲ្យកូនធ្វើអីគេ
កាលហ្នឹង?

សឿនៈ ចឹងចង់ឲ្យរៀនក្រែងលោបានធ្វើការងារអីហ្នឹងគេចឹងទៅណា ។

សុវណ្ណៈ ចឹងមានដែលនឹកស្រម៉ៃម៉េចចង់ឲ្យកូនធ្វើគ្រូបង្រៀនចង់ឲ្យធ្វើអីមួយ ចង់ឲ្យធ្វើគ្រូពេទ្យមានទេ?

សឿនៈ ចេះតែនឹកដែរ កូនខ្ញុំអាមួយនោះចេះពេទ្យបន្តិចៗ ចង់ដែលចង់ឲ្យវាធ្វើពេទ្យអីគ្រាន់យើង
ឈឺស្រួល វាមិនបានធ្វើ ឥឡូវអាងថាយើងមិនមានលុយដដែលបាន មានតែកូនគេអ្នក
មាន គេមានលុយសូកលុយបុកអី ដល់ចឹងអត់ទេ ធ្វើស្រែទៅ ។

សុវណ្ណៈ អ៊ំមានបងប្អូនប៉ុន្មាននាក់ បងប្អូនបង្កើត?

សឿនៈ ខ្ញុំមាន៥នាក់ ។

សុវណ្ណៈ ចឹងប្រុសប៉ុន្មានស្រីប៉ុន្មាន?

សឿនៈ ប្រុស៣ស្រី២ ទៅនៅស្រុកនោះ ។

សុវណ្ណៈ ប្រុស៣ស្រី២ទាំងអ៊ំ?

សឿនៈ ចាស!ខ្ញុំមួយប្អូនមួយហ្នឹង ។

សុវណ្ណៈ ចឹងអ៊ីជាកូនទីប៉ុន្មាន?

សឿនៈ ខ្ញុំបងគេ ។

សុវណ្ណៈ ចឹងសព្វថ្ងៃអ៊ីនៅជុំជាមួយបងប្អូនអ៊ីទេ?

សឿនៈ អត់ទេ ប្អូនបង្កើតខ្ញុំនៅឯស្រុកខេត្តកណ្តាលនោះ ។

សុវណ្ណៈ អ៊ីមានស្រុកកំណើតនៅណា?

សឿនៈ ភូមិពាម ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ។

សុវណ្ណៈ ឃុំ?

សឿនៈ ព្រៃពួច ។

សុវណ្ណៈ ចឹងបងប្អូនសព្វថ្ងៃនៅខេត្តកណ្តាលទាំងអស់?

សឿនៈ ខេត្តកណ្តាល៣នាក់នៅកំពង់ចាមម្នាក់ ។

សុវណ្ណៈ អ៊ីនៅនេះគេហៅភូមិអីគេ?

សឿនៈ ភូមិទួលប្រាសាទ ។

សុវណ្ណៈ ឃុំ?

សឿនៈ ទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ។

សុវណ្ណៈ ទំនប់ដាច់នៅខាងណាវិញអ៊ី?

សឿនៈ ទំនប់នៅខាងនោះ ។

សុវណ្ណៈ មូលហេតុអីបានជាគេដាក់ឈ្មោះ ទំនប់ដាច់?

សឿនៈ មិនដឹងយ៉ាងម៉េចទេ ជំនាន់តាម៉ុក មកខ្ញុំពីដើមមកនៅនោះទេ ហើយខាង០៥គេយកមក ទំនប់០៥អីជីង ទំនប់នេះឯង គេហៅទំនប់ដាច់ក៏ហៅតាមដែរ ។

សុវណ្ណៈ ចឹងទំនប់ហ្នឹងពីណាគេអ្នកធ្វើ?

សឿនៈ តា០៥ ។

សុវណ្ណៈ គាត់កេណ្ឌប្រជាជនឲ្យធ្វើ?

សឿនៈ ចាស!ទប់ទំនប់ជុំវិញរហូត ។

សុវណ្ណៈ ហើយតា០៥គាត់គ្រប់គ្រងពីណាដល់ណា កាលហ្នឹង?

សឿនៈ ពីដើមគាត់នៅកងពល៨០១ ខ្ញុំមិនសូវបានតស៊ូទាន់និងគេទេ ខ្ញុំទើបមកឆ្នាំ៧៧ដែរ ខ្ញុំមក កងពល៨០១ហ្នឹង ខ្ញុំពីដើមខ្ញុំនៅកងចល័តទេ ។

សុវណ្ណៈ ចឹងខ្ញុំចង់ដឹងប្រវត្តិភូមិហ្នឹងសិន កាលពីដើមតា០៥ជាអ្នកគ្រប់គ្រង?

សឿនៈ ចាស ។

សុវណ្ណៈ តា០៥ឈ្មោះគាត់អីគេ?

សឿនៈ ឈ្មោះ តាសា រឿន តែមិនដឹងជាជីតាគាត់ឈ្មោះអីទេ ។

សុវណ្ណៈ សួរ សឿន ឬមួយអីគេ?

សឿនៈ ដឹងអីគេហៅតែតាសា រឿនៗហៅតា០៥ ។

សុវណ្ណៈ ចឹងគាត់គ្រប់គ្រងកងពល៨០១?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងគាត់គ្រប់គ្រងភូមិណាខ្លះទាំងអស់?

សឿនៈ នៅប៉ែកខាងនេះកងគាត់ហ្នឹងឯង គាត់កងពលធំគេហ្នឹងណាស់ ។

សុវណ្ណៈ ចឹងនៅហ្នឹងភាគច្រើនជាកងពល៨០១?

សឿនៈ ចាស ។

សុវណ្ណៈ នៅខាងទំនប់ដាច់នេះ?

សឿនៈ ចាស!ទំនប់ដាច់ត្រពាំងប្រាសាទអីហ្នឹង បើទៅខាងអន្លង់វែងគេហៅតានន់ អីណាខ្ញុំមិនដែលស្គាល់តានន់ ។

សុវណ្ណៈ អ៊ីកាលហ្នឹងឈប់រៀនពេលណាទៅ?

សឿនៈ ខ្ញុំនៅស្រុកហ្នឹងឈប់តាំងពីគេរដ្ឋប្រហារឆ្នាំ៧៣នោះ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ពីដើមដល់ខ្ញុំរត់ទៅនៅស្រុកគេនោះ ជិតបសេដ្ឋកាត់ភ្លុកអីនោះ ខ្មែរក្រហមគេវាយជម្លៀសទៅ កាលហ្នឹងខ្ញុំនៅក្មេងៗដែលហ្នឹង ។

សុវណ្ណៈ ចឹងកាលហ្នឹងអ៊ីឈប់រៀនថ្នាក់ទី១០?

សឿនៈ ចាស!ខ្ញុំកាលហ្នឹងទី១០មិនទាន់ចប់ផង ខ្ញុំចូលបានពាក់កណ្តាលហើយបានខ្មែរក្រហមចូលទៅដល់ ។

សុវណ្ណៈ អ៊ីឈប់រៀនមុនរដ្ឋប្រហារឬមួយក្រោយរដ្ឋប្រហារ?

សឿនៈ ខ្ញុំនេះហើយតើ រដ្ឋប្រហារវាយមកខាងតំបន់ខ្ញុំហើយតើ គ្រាន់វាមិនទាន់បែកភ្នំពេញ ។

សុវណ្ណៈ ខ្ញុំចង់និយាយថា រដ្ឋប្រហារជំនាន់ លន់ នល់ សិន អ៊ីកាលហ្នឹងឈប់រៀនមុនរដ្ឋប្រហារទម្លាក់សម្តេច?

សឿនៈ ខ្ញុំនៅដែលតើ លន់ នល់ ហ្នឹង ។

សុវណ្ណៈ ចឹងមានន័យថា រដ្ឋប្រហារហើយអ៊ីនៅរៀនដដែលទេ?

សឿន: ចូលរដ្ឋប្រហារ លន់ នល់ បានប៉ុន្មានក៏ពួកព្រៃតស៊ូចូលមកភូមិហ្នឹង គេជ្រៀសប្រជាជនអីទៅ ខាងខ្ញុំក៏អត់ហ៊ានមករៀននៅសាលាដែរ ។

សុវណ្ណៈ អ៊ីកាលហ្នឹងមានចាំទេ អ៊ីឈប់រៀនឆ្នាំណា?

សឿន: មិនដឹងថាឆ្នាំណាទេ អាច៧២-៧៣ហ្នឹង ព្រោះ៧៣ខ្ញុំរត់ហើយ ខ្ញុំឈប់ហើយឈប់ទៅ អាចទំនង៧២-៧៣ ហ្នឹងឯង ។

សុវណ្ណៈ អ៊ីឈប់ហើយបានប៉ុន្មានខែ បានរត់ទៅ?

សឿន: ខ្ញុំរត់ហើយនៅភូមិទាំងអស់ ប៉ុន្មានខែ គ្រាប់ផ្លោងខ្ញុំមិនហ៊ានទៅណា ច្រូលច្របល់បានប្រហែលជាប៉ុន្មានយន្តហោះទម្លាក់ភូមិខ្ញុំក៏រត់រហូត ។

សុវណ្ណៈ ចឹង៧២អ៊ីឈប់រៀន?

សឿន: ចាស ។

សុវណ្ណៈ ចឹងមុនរដ្ឋប្រហារហ្នឹងខ្ញុំចង់ដឹងថា ជីវភាពរស់នៅរបស់អ៊ីយ៉ាងម៉េចដែលជាមួយឪពុកម្តាយហ្នឹង?

សឿន: ខ្ញុំមានអីដែលក្អួយឪពុកម៉ែខ្ញុំក្រដែរ មិនមានដែលធម្មតា ។

សុវណ្ណៈ ឪពុកម្តាយអ៊ីធ្វើអីគេ?

សឿន: ឪពុកខ្ញុំធ្វើស្រែចម្ការដែលហ្នឹង មានធ្វើអីធ្វើស្រែដែលហ្នឹង ។

សុវណ្ណៈ ឪពុកឈ្មោះអីគេ?

សឿន: ឪពុកខ្ញុំឈ្មោះ ខាត់ ។

សុវណ្ណៈ ខាត់អី?

សឿន: ជីតាគាត់ ជីតាគាត់មិនដឹងឈ្មោះអីទេ បើឪពុកគាត់ឈ្មោះ តាហួរ តាខ្ញុំ ។

សុវណ្ណៈ ចឹងឪពុកឈ្មោះ ខាត់?

សឿន: ចាស ។

សុវណ្ណៈ ម្តាយ?

សឿន: ម្តាយខ្ញុំឈ្មោះ ឈឿន ។

សុវណ្ណៈ ចឹងគាត់ខូចហៅនៅសព្វថ្ងៃនេះ?

សឿន: គាត់ខូចអស់ហើយ ទើបខូចប្រហែលជាពីរឆ្នាំហ្នឹងឯង ឪពុកខ្ញុំខូចយូរដែលហើយ ។

សុវណ្ណៈ ចឹងម្តាយទើបខូចបានពីរបីឆ្នាំទេ?

សឿន: ចាស ។

សុវណ្ណៈ គាត់ឈឺអីគេ?

សឿនៈ	គាត់ឈឺចាស់ហើយ គាត់៨០ជាង ។

សុវណ្ណៈ	ហើយឪពុកគាត់ខូចពេលណា?

សឿនៈ	ខូចយើងជំនាន់ខ្មែរក្រហមនោះ គាត់រត់ទៅខ្ញុំក៏រត់មកនេះដែលមក ។

សុវណ្ណៈ	ជំនាន់ខ្មែរក្រហមគ្រប់គ្រងប្រទេសឬក៏?

សឿនៈ	ជំនាន់ខ្មែរក្រហមគ្រប់គ្រងប្រទេសហើយណា ។

សុវណ្ណៈ	ចឹងស្លាប់ក្នុងរបបខ្មែរក្រហម?

សឿនៈ	ចាស ។

សុវណ្ណៈ	ស្លាប់ដោយសារអីគេ?

សឿនៈ	ដឹងយ៉ាងម៉េច គាត់ឈឺអីដឹង កាលហ្នឹងម៉េចមានខ្សែរយៈខ្ញុំមកនៅវីនសៃរតនគិរីនេះ ។

សុវណ្ណៈ	ចឹងអឹកុំអាលខ្ញុំសួរនេះសិន ព្រោះខ្ញុំតាមមិនទាន់អី ចឹងចេះតែហួស ខ្ញុំសួរត្រឹមណាត្រឹមកន្លែងហ្នឹងសិន ខ្ញុំចង់ថា ឪពុកស្លាប់នៅក្នុងរបបខ្មែរក្រហម?

សឿនៈ	ចាស ។

សុវណ្ណៈ	ហើយគាត់ស្លាប់ដោយសារអីអឹមានចាំបានទេ កាលហ្នឹង?

សឿនៈ	គាត់ថា ឈឺដែលខ្ញុំនៅនេះ ម៉ែខ្ញុំគាត់នៅឯណោះ មិនដឹងថា គាត់ឈឺអី ។

សុវណ្ណៈ	ចឹងមុនពេលរដ្ឋប្រហារហ្នឹង សភាពការណ៍នៅក្នុងភូមិអឹយ៉ាងម៉េចដែរ យើងរស់នៅធម្មតាសប្បាយទេ?

សឿនៈ	កាលខ្ញុំចេញមកបែកភ្នំពេញហើយខ្ញុំនៅនោះ ខ្ញុំអត់មាននៅស្រុកភូមិខ្ញុំទេ ខ្ញុំនៅខាងតាខ្មៅនោះ ។

សុវណ្ណៈ	ខ្ញុំចង់និយាយថា មុនរដ្ឋប្រហារមុនឆ្នាំ៧០ សភាពការណ៍នៅក្នុងភូមិសុខសប្បាយ?

សឿនៈ	សុខសប្បាយហ្នឹងហើយ សភាពអត់ស្រួលហ្នឹងហើយខ្ញុំរត់ ខ្ញុំរត់គេវាយនៅខាងព្រៃពួចអីហ្នឹងគេជម្លៀសប្រជាជនទៅត្បូង ។

សុវណ្ណៈ	ចឹងពេលរដ្ឋប្រហារហើយលន់ នល់ ទម្លាក់សម្តេច ហើយនោះសភាពការណ៍នៅក្នុងភូមិយ៉ាងម៉េចដែរ?

សឿនៈ	ភូមិខ្ញុំគ្មានប្រជាជននៅទេ គេនៅតែស្រុកត្បូងអ្នកដែលគេរត់មកតាមទាហ៊ាន គេរត់មកទាហានខាងបែកចាននេះ ហើយអ្នកនៅរស់ដូចខ្ញុំចឹងគេ គេជៀសទៅព្រៃក៏ទៅព្រៃ នៅព្រៃទៅភូមិខ្ញុំនៅព្រៃទេ ។

សុវណ្ណៈ	ពីណាគេជម្លៀសអឹទៅ?

សឿនៈ	ជំនាន់ប៉ុល ពត ហ្នឹង ។

សុវណ្ណៈ	ខ្មែរក្រហមជម្លៀសទៅ?

សឿនៈ	ចាស ។

សុវណ្ណៈ	ហើយគេមកជម្លៀសហ្នឹង ជម្លៀសឆ្នាំណា?

សឿនៈ	ជម្លៀសឆ្នាំ៧៣ហើយគេមកជម្លៀសវាយទាំងយប់ ។

សុវណ្ណៈ	ចឹងឆ្នាំ៧៣ខ្មែរក្រហមចូលមកភូមិអ៊ីជម្លៀសប្រជាជន?

សឿនៈ	ចាស ។

សុវណ្ណៈ	គេជម្លៀសនាំទៅណា?

សឿនៈ	គេនាំទៅបរសេដ្ឋកាត់ក្តុកនោះ នៅអីខាងស្រុកត្បូងនោះ ។

សុវណ្ណៈ	ចឹងខ្មែរក្រហមគៀអ៊ឹទៅ?

សឿនៈ	ចាស ។

សុវណ្ណៈ	គៀប្រជាជនពីភូមិអ៊ឹទៅ?

សឿនៈ	ចាស!បរទេះទៅៗ ។

សុវណ្ណៈ	ចឹងមានអ្នកមួយចំនួនរត់ចូលទៅខាងទាហានលន់ នល់ ទៅ?

សឿនៈ	ចាស!អ្នកខ្លះគេនៅហ្នឹងទៅ ខ្លះអ្នកនេះក៏មកចឹងមក គេទៅជម្លៀសទាំងយប់ ។

សុវណ្ណៈ	ចឹងគេជម្លៀសអ៊ឹទាំងគ្រួសារឬមួយគេជម្លៀសអ៊ឹតែម្នាក់ទេ?

សឿនៈ	ទេ ទាំងម៉ែទាំងកូនទាំងអស់គ្នាហ្នឹង ទាំងអ្នកស្រុកនាំគ្នាបរគោរទេះទៅរចេករចាច ។

សុវណ្ណៈ	គេជម្លៀសទៅក្នុងព្រៃឬទៅកន្លែងភូមិផ្សេង?

សឿនៈ	ពីភូមិមួយទៅភូមិមួយគេបញ្ជូនទៅតាមភូមិ គេថាទៅកន្លែងអគ្គការ ។

សុវណ្ណៈ	គេជម្លៀសរហូតទៅនៅណា?

សឿនៈ	ខ្ញុំទៅនៅជិតបរសេដ្ឋកាត់ក្តុកនោះ ។

សុវណ្ណៈ	បរសេដ្ឋកាត់ក្តុកនៅម្តុំណា នៅស្រុកណា?

សឿនៈ	ស្រុកអី ខេត្តកំពង់ស្ពឺ ។

សុវណ្ណៈ	ដល់ឧិរ៉ាល់ទេ?

សឿនៈ	ជិតឧិរ៉ាល់ហ្នឹង ខាងកើតឧិរ៉ាល់ ។

សុវណ្ណៈ	តែហួសឧិរ៉ាល់ទេ?

សឿនៈ	អត់ហួសទេអី ។

សុវណ្ណៈ	ចឹងជម្លៀសទៅខាងបរសេដ្ឋ?

សឿនៈ	ហ្នឹងហើយ បរសេដ្ឋកាត់ក្តុក ។

សុវណ្ណៈ ចឹងក្រោយមកគេជម្លៀសអ៊ីពីស្រុកអង្គស្នួលទៅស្រុកបរសេដ្ឋ?

សឿនៈ ចាស ។

សុវណ្ណៈ ជម្លៀសទៅហ្នឹងគេឲ្យអ៊ីធ្វើអីគេ?

សឿនៈ មានធ្វើស្អីក្មួយ នៅគាស់គល់ដាំដំឡូងជាមួយអ្នកភូមិស្រុកគេហ្នឹង ។

សុវណ្ណៈ អ៊ីមិនទាន់ចូលបដិវត្តជាមួយគេទេ?

សឿនៈ ខ្ញុំមិនចូលទេ នៅជាមួយម៉ែហ្នឹងឯង ។

សុវណ្ណៈ ចឹងឆ្នាំណាបានអ៊ីចូលបដិវត្តជាមួយគេ?

សឿនៈ ខ្ញុំឆ្នាំ៧៣-៧៤-៧៥ហើយហ្នឹង បានខ្ញុំចូលមកធ្វើកងចល័តហ្នឹង ខ្ញុំអត់មានបានទៅធ្វើកងទ័ពទេ ។

សុវណ្ណៈ ខ្ញុំចង់និយាយថា ៧៣គេជម្លៀសអ៊ីទៅ?

សឿនៈ ជម្លៀសទៅទាំងម៉ែទាំងអីទេ ។

សុវណ្ណៈ ជម្លៀសទៅនៅបរសេដ្ឋ?

សឿនៈ ចាស ។

សុវណ្ណៈ ជម្លៀសទៅបានប្រហែលជាប៉ុន្មានខែប៉ុន្មានឆ្នាំ?

សឿនៈ បានប្រហែលជាមួយឆ្នាំជាងខ្ញុំមកវិញ ក្មួយខ្ញុំគេធ្វើទ័ពដែរ ដូចថារំដោះយកខ្ញុំមកវិញណាស់ នៅត្បូងខ្លាចចាញ់ ខ្ញុំបានមកវិញ ។

សុវណ្ណៈ មកទាំងគ្រួសារ?

សឿនៈ ចាស!មកទាំងម៉ែទាំងអីមកនៅហ្នឹង ។

សុវណ្ណៈ មកនៅណា?

សឿនៈ មកដល់ភូមិមកនៅពោធិឃុំខាងត្បូងភូមិខ្ញុំ ។

សុវណ្ណៈ ចឹងមកនៅស្រុកវិញ?

សឿនៈ ចាស!មកនៅជិតស្រុកហ្នឹង ។

សុវណ្ណៈ ចឹងទៅនៅបរសេដ្ឋមួយឆ្នាំមកនៅស្រុកវិញ?

សឿនៈ ចាស!មកនៅមិនដល់ចូលភូមិទេ មកនៅជិតភូមិមកនៅពោធិឃុំ ខាងត្បូងភូមិខ្ញុំម្នាងស្អីងម្នាក់គ្រាន់ថ្ងៃអីយើងមកលេងមួយភ្លេចៗអី ។

សុវណ្ណៈ កាលហ្នឹងឆ្នាំណា?

សឿនៈ ឆ្នាំ៧៤ហើយ ។

សុវណ្ណៈ ចឹងឆ្នាំ៧៤ត្រឡប់មកវិញ?

សឿនៈ ចាស ។

សុវណ្ណៈ ដើមឆ្នាំ៧៤ពាក់កណ្ដាលឬឆ្នាំ៧៤?

សឿនៈ យី!ដើមឆ្នាំទេក្មួយ កាលហ្នឹងមិនដល់មួយឆ្នាំទេ អាចឆ្នាំ៧៣អាចចុង ខ្ញុំមកហ្នឹងនៅស្រូវអី ដែរ តែខ្ញុំមិនបានចំណាំច្បាស់ កាលហ្នឹងនៅក្មេងៗដែរ ។

សុវណ្ណៈ ចឹងនៅជាមួយគេរហូតទៅឆ្នាំ៧៤នៅជាមួយខ្មែរក្រហមរហូតទៅ?

សឿនៈ ចាស ។

សុវណ្ណៈ ដល់ពេលឆ្នាំណាបានគេឲ្យអី?

សឿនៈ នៅពេលឆ្នាំ៧៥នេះ គេវាយភ្នំពេញបែក គេខ្ញុំទៅនៅកងចល័តហ្នឹងគេឲ្យខ្ញុំទៅធ្វើប្រធាន នារីនៅហ្នឹង ។

សុវណ្ណៈ ចឹងឆ្នាំ៧៥អីចូលកងចល័ត?

សឿនៈ ចាស!គេឲ្យធ្វើប្រធាននារីនៅតាមភូមិមុនដំបូងនោះ ។

សុវណ្ណៈ ចូលដំបូងកងចល័តអីគេ?

សឿនៈ ខ្ញុំនៅក្នុងភូមិកងចល័តអីទេ ។

សុវណ្ណៈ ចល័តភូមិ ចល័តឃុំ ចល័តស្រុក?

សឿនៈ មើលមុនដំបូងភូមិចេះ ។

សុវណ្ណៈ ចឹងដំបូងចល័តភូមិទេ?

សឿនៈ ចាស!នៅភូមិនេះឯង ។

សុវណ្ណៈ ចឹងអត់មានទៅធ្វើការនៅណាឆ្ងាយទេ?

សឿនៈ ចាស!ខាងខ្ញុំហ្នឹងតំបន់១៥ ពិបាកគេឲ្យធ្វើប្រធាននៅគ្រប់គ្រងនារីក្នុងភូមិចេះ ។

សុវណ្ណៈ ចឹងពេលខ្មែរក្រហមគ្រប់គ្រងប្រទេសអីនៅកំពង់ស្ពឺទេ?

សឿនៈ អត់មានទេ ។

សុវណ្ណៈ អូ!នៅខេត្តកណ្ដាលទេ?

សឿនៈ ចាស!មួយសារខ្ញុំមកពីបរសេដ្ឋហ្នឹងខ្ញុំមកនៅពោធិយំ មិនដល់ភូមិខ្ញុំទេ ។

សុវណ្ណៈ ចឹងភូមិពោធិយំ?

សឿនៈ ភូមិពោធិយំមិនដឹងជាស្រុកស្អីគេ ស្រុកគងពិសីម្ខាងស្ទឹងម្នាក់ទេ ។

សុវណ្ណៈ ស្រុកគងពិសីមានតែកំពង់ស្ពឺ?

សឿនៈ អត់ដល់កំពង់ស្ពឺទេ ដូចថាភូមិខ្ញុំចឹង ខ្ញុំនៅម្ខាងស្ទឹងម្នាក់ ជម្លៀសនៅហ្នឹងបានប៉ុន្មានខែទា ហានចូលគៀប្រជាជន ទាហានវាឆ្លងស្ទឹងទៅគៀប្រជាជន ។

សុវណ្ណៈ	ទាហានខាងណា?

សឿនៈ	ទាហាន លន់ នល់ យើងហ្នឹង ចុះទៅពួកខ្ញុំនោះទាហានមិនបានគៀទេ ព្រឹកឡើងចឹង ជម្លៀសទៅនៅអន្លង់តាប្រ៉ុចទៀត នៅជិតស័ង្កសីណាស់ ។

សុវណ្ណៈ	ចឹងពេលឆ្នាំ៧៥ នោះគេឲ្យអ៊ីចូលកងចល័ត?

សឿនៈ	អាហ្នឹងនៅតាមភូមិមិនទាន់ចេញពីម៉ែ គេឲ្យនៅមើលការខុសត្រូវនារី ពួក៧៥ចូលទៅ ។

សុវណ្ណៈ	ពួក១៧មេសា?

សឿនៈ	ចាស ។

សុវណ្ណៈ	ចឹងអ៊ីប្រជាជនមូលដ្ឋានទេ?

សឿនៈ	ចាស ។

សុវណ្ណៈ	ពេលឆ្នាំ៧៥ គេអត់មានជម្លៀសអ៊ីទៅណាទេ?

សឿនៈ	អត់ទេ អាហ្នឹងខ្ញុំមិនមែននៅក្នុងភូមិខ្ញុំទេ ខ្ញុំមកនៅខាងស្ពានថ្ម ភូមិជិតព្រែកហូរនេះ ។

សុវណ្ណៈ	តែអ៊ីជាមូលដ្ឋាននៅហ្នឹងទេ?

សឿនៈ	ចាស!នៅក្នុងភូមិចឹងឯង គ្រាន់ខ្ញុំនៅធ្វើការជាមួយពួកយាយផលអីចឹង ។

សុវណ្ណៈ	ចឹងកាលហ្នឹងអ៊ីចូលកងចល័តនារី?

សឿនៈ	អត់ទាន់បានចូលកងចល័តនារីទេ កាលឆ្នាំ៧៥ នោះដល់៧៦នោះ នៅតាមភូមិ ។

សុវណ្ណៈ	តែដំបូងចាប់ឲ្យយើងធ្វើកងចល័តទេ?

សឿនៈ	ចាស ។

សុវណ្ណៈ	តែកងចល័តនៅក្នុងភូមិទេ អត់មានទៅណាទេ?

សឿនៈ	ចាស!ឆ្នាំ៧៦ដើរធ្វើទំនប់ធ្វើប្រឡាយចឹងទៅ ។

សុវណ្ណៈ	អាហ្នឹងចូលចល័តឃុំហើយ?

សឿនៈ	ចាស!ចូលមកចល័តតំបន់គេ ចេញពីភូមិហើយហ្នឹងណាស់ ចូលឃុំណាៗកន្លែងស្រុកគេហ្នឹង មកដូចជាធ្វើការទំនប់អីណាទេ ។

សុវណ្ណៈ	ចឹងយើងចល័តពីឃុំមួយទៅឃុំមួយ?

សឿនៈ	ចាស!ហ្នឹងហើយ ។

សុវណ្ណៈ	ចឹងយើងមានចល័តទៅស្រុកមួយទៀតទេ?

សឿនៈ	ចាស!ដូចជាត្រូវគេយកទៅធ្វើការទំនប់ប្រឡាយណា គេយកទៅក៏ទៅតាមគេចឹងទៅ ។

សុវណ្ណៈ	គេហៅចល័តអីគេកាលហ្នឹង?

សឿនៈ	ចល័តស្រុកដឹង ខ្ញុំក៏មិនសូវដឹងដែរ ។

សុវណ្ណៈ	ចល័តស្រុក?
សឿនៈ	ចាស ។
សុវណ្ណៈ	ក្នុងមួយកងចល័តស្រុកអឹមានគ្នាប៉ុន្មាននាក់?
សឿនៈ	មានច្រើនតើក្មួយមាន១០០០ដីងខ្ញុំមិនមែនធ្វើប្រធានកងគេដង ។
សុវណ្ណៈ	ហើយអឹកាលហ្នឹងគេឲ្យធ្វើអីគេ?
សឿនៈ	ខ្ញុំគ្រាន់ធ្វើប្រធានក្រុម ។
សុវណ្ណៈ	ប្រធានក្រុមគ្រប់គ្រងគ្នាប៉ុន្មាននាក់?
សឿនៈ	១២នាក់ ។
សុវណ្ណៈ	ហើយភាគច្រើននាក់មកពីណា?
សឿនៈ	សុទ្ធអ្នក១៥ នៅតាខ្មៅហ្នឹង នៅស្ពានថ្មព្រែកហូរអីហ្នឹងណាស់ គ្នាយើងនៅតាមភូមិអីហ្នឹង អ្នក១៧មេសាខ្លះ គេនៅភ្នំពេញអីណាស់ ដូចថាយើងអ្នកចាស់អ្នកថ្មីនៅ ដូចថាអ្នកថ្មីគ្នាទើបទៅពីភ្នំពេញហ្នឹង មិនសូវចេះធ្វើការដូចជាអ្នកស្រែយើង ។
សុវណ្ណៈ	ចឹងឆ្នាំ៧៦អឹចាប់ផ្ដើមបែកពីឪពុកម្ដាយហើយ?
សឿនៈ	ចាស ។
សុវណ្ណៈ	បែកពីបងប្អូនហើយ?
សឿនៈ	ចាស ។
សុវណ្ណៈ	ទៅនៅជុំជាមួយកងចល័ត?
សឿនៈ	ចាស ។
សុវណ្ណៈ	ចឹងពេលនៅបែកចឹង ចុះបងប្អូនអឹទៀតមានបានដឹងដំណឹងទេ ថាយ៉ាងម៉េចយ៉ាងម៉ាខ្លះ?
សឿនៈ	ខ្ញុំបងប្អូនខ្ញុំ ខ្ញុំដឹងដែលតើ ខ្ញុំនៅចល័តស្រុក គ្រាន់ប្អូនខ្ញុំគេនៅកន្លែងកុមារ ។
សុវណ្ណៈ	ចឹងប្អូនផ្សេងៗទៀត?
សឿនៈ	ប្អូនផ្សេងទៀតពីរនាក់នោះនៅកន្លែងកុមារហើយអាពីរនាក់នោះនៅតូចៗវានៅជាមួយម៉ែខ្ញុំ ម៉ែខ្ញុំដឹបូងគាត់ដើរធ្វើការដែលហ្នឹង ដល់ក្រោយមកគេឲ្យគាត់នៅធ្វើអង្ករកន្លែងកិនស្រូវគេហ្នឹង ។
សុវណ្ណៈ	ចឹងកាលអឹនៅកងចល័តឆ្នាំ៧៥នោះ កាលហ្នឹងការងារគេឲ្យធ្វើអីខ្លះ?
សឿនៈ	ខ្ញុំមិនសូវធ្វើអីទេ ខ្ញុំកាលហ្នឹងខ្ញុំខស្សាហ៍ឈឺ គ្រាន់ថានារីៗលើករងដំឡូងលើកទំនប់ខ្ញុំក៏ចេះតែទៅដែរ តែខ្ញុំអត់សូវបានការងារខ្ញុំចាញ់ខ្ញុំឈឺ ។
សុវណ្ណៈ	កាលហ្នឹងអឹអាយុប៉ុន្មាន?

សឿនៈ ខ្ញុំ១៦-១៧ហ្នឹង១៧-១៨ហ្នឹង ។

សុវណ្ណៈ ចឹងពេលចូលមកដល់ចល័តស្រុកនេះ ការងារយើងធ្វើអីខ្លះ ខែវស្សាធ្វើអីគេ?

សឿនៈ ខែវស្សាស្ទូងស្រែដូចយើងដែរ ។

សុវណ្ណៈ ខែប្រាំង?

សឿនៈ ប្រាំងបេះទៅលើកទំនប់ បើដើមឆ្នាំនោះទប់ភ្លឺស្រែ ក្រឡាឈើត្រង់គេនោះ គេចែកម្នាក់ប៉ុន្មានម៉ែត្រ មួយក្រុមយើងមិនដឹងជាប៉ុន្មានរយម៉ែត្រចឹងទៅមួយថ្ងៃ ចែកគ្នានៅមួយក្រុមចឹងទៅ ។

សុវណ្ណៈ ហើយការងារយើងធ្វើពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ព្រលឹមឡើងចាប់ផ្ដើមម៉ោងប៉ុន្មាន?

សឿនៈ ព្រលឹមឡើងធ្វើហើយទំនប់ហ្នឹង យប់ក៏ធ្វើដែរ ។

សុវណ្ណៈ យប់យើងធ្វើដល់ម៉ោងប៉ុន្មាន?

សឿនៈ ក្រុមយើងហ្នឹង ដូចថាយើងចង់ឆាប់ហើយយើងត្រឹមម៉ោង៩ឈប់ ខ្លះគេនៅដល់ម៉ោង១០ក៏ដល់ទៅ ខ្ញុំមិនសូវប៉ុនដែលខ្ញុំដល់ម៉ោង៩អីឈប់ហើយ ។

សុវណ្ណៈ ចឹងការហូបចុកពេលហ្នឹងយ៉ាងម៉េចដែលអ៊ំ?

សឿនៈ ការហូបចុកបើបាយមិនខ្វះទេ បើសម្លហូបវាមិនកើត ។

សុវណ្ណៈ យ៉ាងម៉េចបានជាហូបមិនកើត?

សឿនៈ សម្លត្រកួនអីហ្នឹង ទឹករលីងរលោងហូបវាមិនឆ្ងាញ់ណា មួយខ្ទះៗមួយក្រុមមានតែយកបាយពីរនាក់ម្នាក់កាន់បាយមួយនាក់សម្លក្រុមខ្ញុំមួយកាធុនបេះ មកបាយមួយការធន់សម្លគេហ្នឹង វាសម្បូរតែសម្លត្រកួនទឹករលីងរលោង ។

សុវណ្ណៈ យើងមានប្រាប់គេឲ្យគេធ្វើនេះធ្វើនោះ មានដែលប្រាប់ចុងភៅខ្លះទេ?

សឿនៈ មិនដែលហ៊ានប្រាប់ទេ ។

សុវណ្ណៈ ចឹងមានរអ៊ូរទាំអីខ្លះទេ រឿងហូបចុកខ្លះទេ?

សឿនៈ ទោះបីរអ៊ូតែគ្នាឯងហ្នឹងមិនដែលនិយាយឲ្យគេឮទេ ខ្លាចគេយកទៅណាទៅណីដែរ ។

សុវណ្ណៈ ម៉េចបានខ្លាចគេយកទៅណា?

សឿនៈ ចុះបេះតែខ្លាចហើយក្នុយឃើញគេអ្នកភ្នំពេញ១៧មេសាអី ឮគេថាបេះថាចុះ ។

សុវណ្ណៈ ឮគេថាយ៉ាងម៉េច?

សឿនៈ ចុះឮគេថាអ្នក១៧មេសាមិនសូវប៉ុនធ្វើការ គេយកទៅកន្លែងលុតដុំ បើថាហូបអីមិនឆ្ងាយដូចថាមួយក្រុមខ្ញុំទៅផ្ទះចឹង អ្នកផ្ទះគេនៅខាងព្រែកហូរអីបានត្រីបានសាច់មកហូបក្រុមហ្នឹងទៅ ។

សុវណ្ណៈ ចឹងអ្នកដែលទៅកន្លែងលត់ដុំហ្នឹងភាគច្រើនឃើញគេមកវិញទេ?

សឿនៈ ចាស! ទៅបាត់ទៅមិនដឹងជាទៅណាយើងចេះតែខ្លាចទៅ មិនដឹងជាគេយកទៅណាដែរ ។

សុវណ្ណៈ អឺមានដេលសួរនាំទេ សួរនាំបងប្អូនអ្នកគេនាំទៅទេ?

សឿនៈ មិនដែលទេ បើអ្នកជិតខ្ញុំដែលសួរគេ គាត់ថាដឹងយ៉ាងម៉េចទេ ខ្លះខាងខ្ញុំមកកាប់ដីគៀនៗ ថ្នល់ជាតិអីហ្នឹង ខ្ញុំកងចល័តអីមកបុណ្យមេទិញនៅកន្លែតមិនដែលឃើញអីដែរ ដូចកាប់តាមផ្ទះមានថ្មអីនាំគ្នាកាប់ខ្ទីសៗ ។

សុវណ្ណៈ កាប់អីគេ?

សឿនៈ កាប់ផ្លាកដីគេឲ្យផ្លាកដីដាំដំឡូងអីណា ឃើញមកយើងស្គាល់ចឹងទៅ ។

សុវណ្ណៈ ចឹងប្រជាជនមូលដ្ឋាននិងប្រជាជនថ្មីចូលមកនៅមានលក្ខណៈខុសគ្នា?

សឿនៈ នៅជាមួយគ្នាហ្នឹង គ្រាន់គេអ្នក១៧មេសាហ្នឹងនៅដូចតែយើងដែរ ដល់ពេលណាគេត្រូវជ្រើសរើសយកទៅណា គេថាអ្នកមកថ្មីចឹងគេយកទៅរៀនសូត្រអីចឹងណា គេយកចុចឈ្មោះថា ផ្ទះខ្ញុំចឹងត្រូវយកកូនខ្ញុំអាមួយណាអី គ្រាន់ឧទាហរណ៍ យកអានេះមួយអានោះពីរទៅ មួយឃុំចឹងដាក់មួយឡានទៅ ខ្ញុំមិនដែលជួបប្រទះទេខ្ញុំផ្តាច់ខ្លួននៅតែម៉ែអីហ្នឹង ទើបបែក៧៥ - ៧៦ហ្នឹង ។

សុវណ្ណៈ ចឹងអឺមានដែលឃើញគេវាយធ្វើបាបមនុស្សទេនៅក្នុងរបបខ្មែរក្រហមហ្នឹង?

សឿនៈ ខ្ញុំមិនដែលជួបទេ ។

សុវណ្ណៈ ចឹងដែលឃើញអ្នកដែលគេយកទៅរៀនសូត្រ?

សឿនៈ ចាស! ដែលឃើញ ។

សុវណ្ណៈ ចឹងមានដែលឃើញអ្នកដែលគេយកទៅរៀនសូត្របានត្រឡប់មកវិញទេ?

សឿនៈ អត់ទេ ។

សុវណ្ណៈ ចឹងអឺមានដែលឆ្ងល់ក្នុងខ្លួនខ្លះថាគេយកទៅណាទៅណី?

សឿនៈ ចាស! ចេះតែឆ្ងល់ហើយគេយកទៅបានប៉ុន្មានខែហើយខ្ញុំក៏បែកជាមួយគាត់ នៅកងចល័តដែលហ្នឹង ។

សុវណ្ណៈ តែខ្លួនអីផ្ទាល់គិតថាយ៉ាងម៉េចពេលហ្នឹង?

សឿនៈ ចេះតែគិតឃើញដែលហ្នឹង ដឹងថាគេយកទៅណា ។

សុវណ្ណៈ ហើយមានដែលសួរនាំគ្នាអ្នកជិតខាងធ្វើការជាមួយគ្នាទេ?

សឿនៈ ខ្ញុំមិនសូវហ៊ានសួរទេខ្លាច ខ្លាចគេតាមដានអីយើង ។

សុវណ្ណៈ គេតាមដានយើងយ៉ាងម៉េចអឺ?

សឿនៈ ខ្លាចគេតាមដានយើងនិយាយចេះនិយាយចុះ លោយើងនិយាយខុសអីទៅ ខ្លាចលោគេយកដែលហ្នឹង ម្ល៉ោះហើយអត់មានសួរដែលសួរនាំអីទេ ធ្វើមិនឃើញហើទៅ ។

សុវណ្ណៈ ចឹងពេលអ៊ំមកធ្វើការនៅក្នុងកងចល័តឆ្នាំ៧៦ហ្នឹង តើការងារលំបាកឬមិនសូវលំបាកទេ?

សឿនៈ ការងារខាងខ្ញុំដូចជាមិនសូវអីដែលទេ ឃើញខាងគេថាលំបាក ខាងខ្ញុំធ្វើទាំងយប់ក៏ឲ្យធ្វើដែរ ពីប្រលប់ម៉ោង៧ចូលចឹងដល់ម៉ោង៩សម្រាកដែរ ដល់ខែវស្សាហ្នឹងអត់ធ្វើទេយប់ ។

សុវណ្ណៈ ចឹងមានន័យថា ការងារសម្រាប់ប្រជាជនមូលដ្ឋានមិនសូវធ្ងន់ធ្ងរដូចជាប្រជាជនថ្មី?

សឿនៈ ប្រជាជនថ្មីប្រជាជនមូលដ្ឋានអី ដល់ពេលហ្នឹងដាក់ចូលគ្នាទាំងអស់ហ្នឹង បើគេចង់ឲ្យការងារអ្នកមូលដ្ឋានហ្នឹង គេយកទៅអ្នកថ្មីៗហ្នឹង តែមីងៗអ្នកមកថ្មីដែលនៅជាមួយយើងមានអីទេ នៅដូចតែយើងដែលហ្នឹង ។

សុវណ្ណៈ ចឹងនៅក្នុងក្រុមអ៊ំមានអ្នកថ្មីទេ?

សឿនៈ មានដែលតើ ធ្វើការដូចតែយើងដែលហ្នឹង ។

សុវណ្ណៈ គ្នាធ្វើការយ៉ាងម៉េចទៅពេលហ្នឹង?

សឿនៈ ធ្វើវាមិនសូវបានទេ តែខាងខ្ញុំមិនសូវអីទេ ព្រោះអីធ្វើការយ៉ាប់គ្នាធ្វើជាមួយតែរាងស្គមៗ ព្រោះគេនៅភ្នំពេញមិនដែលលំបាកនោះ ។

សុវណ្ណៈ ចឹងអ្នកទាំងហ្នឹងមានដែលរអ៊ូរទាំថា ធ្វើមិនកើតអីទេ?

សឿនៈ អត់ទេ ពួកខ្ញុំមួយក្រុមខ្ញុំយល់ហើយ យើងពន្យល់គ្នាយើងចឹងទៅ បើឃើញគ្នាហត់ពេកចឹងនៅមួយថ្ងៃទៅ យើងរាយការណ៍ប្រាប់ខាងលើថា ឈឺចេះចុះទៅគេក៏មិនថាអីដែរ ប៉ះខ្លះយើងមិនស្រួលអីហ្នឹង ឈឺតិចតួចឈប់មួយថ្ងៃទៅ តែវាលំបាកដោយកន្លែងដែលណាកន្លែងខ្ញុំវាមិនថាលំបាកអត់រឿងអត់មានបាយហូបទេ រឿងបាយមិនខ្វះហូបទេ ។

សុវណ្ណៈ ចឹងពេលហ្នឹងអ៊ំធ្លាប់ទៅវត្តទៅវ៉ាជាមួយឪពុកម្តាយ ចឹងនៅក្នុងរបបខ្មែរក្រហមអ៊ំមានបានទៅវត្តទេ បានទៅរៀនសូត្រទេ នឹកឃើញយ៉ាងម៉េចពេលហ្នឹង?

សឿនៈ ខ្ញុំនឹកឃើញដែលតើ ពីដើមខែបុណ្យខែទានចេះចុះ ដល់ពេលយើងមកនេះមិនដែលមានបុណ្យអីទេ មានបុណ្យខែចូលឆ្នាំគេឲ្យបុណ្យដែរ បុណ្យមិទ្ទីងមកជួបជុំគ្នានៅកន្ទួតនេះ ខេត្តកណ្តាលដែលហ្នឹង ។

សុវណ្ណៈ ជួបជុំគ្នាធ្វើអីគេ?

សឿនៈ គេធ្វើមិទ្ទីងស្រែកជ័យយោ គេជប់លៀងកាប់គោកាប់ជ្រូកអីហូបទៅណាស់ ។

សុវណ្ណៈ ចឹងមានបុណ្យមិទ្ទីងបុណ្យខួបរបស់បក្សទេ?

សឿនៈ ចាស!ហ្នឹងហើយបុណ្យមិទ្ទីងបុណ្យខួបដូចថាយើងធ្វើទំនប់ប្រឡាយហើយចឹងទៅគេធ្វើមិទ្ទីង ចឹងណាម្ដងចឹងទៅ ។

សុវណ្ណៈ ចឹងវត្តវ៉ានោះគេយកទៅធ្វើអីវិញ?

សឿនៈ វត្តវ៉ាមិនដែលបានស្គាល់ទេ គេចោលអស់ហើយ ។

សុវណ្ណៈ តែនៅក្នុងភូមិគេចោលគេយកដាក់អីវិញ កន្លែងហ្នឹង?

សឿនៈ វត្តមិនដែលឃើញពីណាយកធ្វើអីទេ គេទុកចោលនៅហ្នឹង អ្នកណាក៏មិនដែលចូលដែលមាន តែយើងកងចល័តនៅជិតហ្នឹង យើងទៅដេកសម្រាកនៅហ្នឹង ។

សុវណ្ណៈ ហើយឃើញក្នុងវត្តហ្នឹងមានអីគេទៅ?

សឿនៈ មានស្អីបើអត់មានលោកមានខបាសកអីផង មានលោមានអីណាបើអស់លោអីហើយ ។

សុវណ្ណៈ តែគេយកដាក់អីវិញកាលហ្នឹង ដូចដាកន្លែងចិញ្ចឹមសត្វឬកន្លែងដាក់គ្រាប់អីទេ?

សឿនៈ បើវត្តកន្លែងខ្ញុំនៅហ្នឹង វត្តប្រធាតុហ្នឹងអត់មានឃើញស្អីផងហ្នឹង អាសាលាហ្នឹងឃើញនៅ តែព្រះវិហារហ្នឹង វាយបែកបាក់អស់ហើយហ្នឹង ។

សុវណ្ណៈ ខាងណាអ្នកវាយ?

សឿនៈ មានខាងណាមានតែខាងយើងដឹង ។

សុវណ្ណៈ ខាងខ្មែរក្រហម?

សឿនៈ ចាស!កាលឆ្នាំ៧៥ហ្នឹងគេវាយបែកទៅខ្ញុំមកនៅវត្តប្រធាតុហ្នឹង ខ្ញុំពីមុននៅអីស្រែព្រៃនោះ ខ្ញុំអត់បានមកភូមិខ្ញុំទេ ខ្ញុំចេញរហូតទាល់តែឥឡូវនេះឯង នៅពោធិយំចេញពីពោធិយំគេ ជម្លៀសខ្ញុំមកពីស្រែព្រៃមក មកស្រែអាយោងចឹងទៅ ។

សុវណ្ណៈ ចឹងដល់ពេលអឹងអត់មានបានគោរពប្រត្តិបត្តិសាសនាអត់មានបានទៅរៀនទៅសូត្រហ្នឹង អ៊ឹ គិតថារបបហ្នឹងយ៉ាងម៉េច ពេលហ្នឹង?

សឿនៈ គេថា គេរបបអីពុករលួយគ្មានវត្តគ្មានវ៉ាខ្ញុំចេះតែគិតខ្លួនឯង ខ្ញុំកាលហ្នឹងនៅក្មេងៗមិនដែរ ទេ ។

សុវណ្ណៈ យើងគិតតែក្នុងចិត្តទេ?

សឿនៈ ចាស ។

សុវណ្ណៈ អត់មានដែលនិយាយចេញមកក្រៅទេ?

សឿនៈ ចាស ។

សុវណ្ណៈ មូលហេតុអីអត់ហ៊ាននិយាយចេញក្រៅ?

សឿនៈ ចេះតែខ្លាចរបបគេហ្នឹង ។

សុវណ្ណៈ ចឹងយើងមានដែលពិភាក្សាជាមួយអ្នកធ្វើការក្នុងក្រុមយើងទេ កងចល័តជាមួយគ្នាហ្នឹងថា និយាយរឿងផលលំបាកពិភាក្សានេះពិភាក្សានោះចឹង រឿននេះរឿងនោះជាមួយគ្នាចឹង មានដែលនិយាយទេ មានដែលមានទេពេលហ្នឹង?

សឿនៈ អត់ទេ មានដែលនិយាយទេ ។

សុវណ្ណៈ ម៉េចបានជាយើងមិនដែលនិយាយចឹង?

សឿនៈ បើមិនហ៊ាននិយាយចេះតែហីទៅ បើខ្ញុំនិយាយទៅមិនទុកចិត្តក្មួយឯង ខ្លាចក្មួយឯងរាយការណ៍ចឹងទៅ ដូចជាក្មួយឯងនិយាយចឹងមិនទុកចិត្តខ្ញុំផ្សេងចឹងទៀតទៅ ម្លោះហើយចេះតែធ្វើទៅគេក៏ធ្វើយើងក៏ធ្វើទៅ មានពីណាមួយតស៊ូមានយោបល់ចេះចុះអីអត់ទេ ។

សុវណ្ណៈ ចុះពេលគេប្រជុំជីវភាពនោះ គេប្រជុំយ៉ាងម៉េចអ៊ី?

សឿនៈ គេប្រជុំតែរឿងធ្វើការងារទេក្មួយ ប្រជុំរឿងធ្វើទំនប់ប្រឡាយក្នុងប្រឡាយហ្នឹងមួយខ្សែ មួយក្រុមយើងមានផែនការប៉ុន្មាន មួយអាទិត្យក្រែងលោ១០ថ្ងៃ យើងហ្នឹងសម្រេចធ្វើបានអីមិនបាន ពេលយើងក្រុមអីចឹង យើងមានយោបល់ថាយើងសម្រេចធ្វើបានឬក៏ធ្វើបានមុនផែនការចឹងទៅណាស់ ។

សុវណ្ណៈ ចឹងមានអ្នកលើកបញ្ហាធ្វើមិនបានទេ?

សឿនៈ ចាស!អត់មានទេ ចឹងពេលខ្លះធ្វើអត់បានដែរ គ្រាន់តែលើធ្វើឲ្យបានសម្រេចតាមផែនការអង្គការដែលដាក់ចុះ សម្រេចឲ្យបានតាមផែនការឬក៏មុនផែនការចឹង តែដល់ធ្វើខ្លះក៏បានមុនខ្លះក៏បានក្រោយ បើពិបាកទៅទំនប់អីអត់បានទេ គេដាក់ផែនការថាកន្លះខែឲ្យហើយចឹងខ្លះណាអត់ហើយទេ យើងពិបាកដីថ្ម គ្រួសច្រើន ។

សុវណ្ណៈ ចឹងដល់ពេលអត់ហើយធ្វើយ៉ាងម៉េចទៅ?

សឿនៈ អត់ហើយចឹង អត់អីដែលហ្នឹង ក៏គេធ្វើមិទ្ទីងទៀតទៅ ។

សុវណ្ណៈ ចឹងអ្នកធ្វើមិទ្ទីងមានដែលលើកបញ្ហាពីរឿងការងារទៅអ្នកដឹកនាំប្រជុំទេ?

សឿនៈ លើកតើ មួយកងចឹងគេឲ្យមានប្រធានៗគេឡើងមានយោបល់ហើយ តែមិនសូវមានថាមិនហើយផង វាមានតិចៗហើយចឹងតែវាមិនបានចាំងដើងទេ ផែនការណ៍គេដាក់មកខាងលើគេសម្រេចដែលហ្នឹង វាមិនបានគ្រប់ចឹងវាមានហេតុផលគេ អាខ្លះថ្មអាខ្លះមានគ្រួសចឹងទៅ គេទៅយកតាសេះមកឲ្យយើងជីកណាស់ គេអត់មានធ្វើអីយើងទេ គេទៅមើលជាក់ស្តែងឃើញថាលំបាកកាប់មិនដាច់ ។

សុវណ្ណៈ ហើយប្រជុំជីវភាពហ្នឹងគេប្រជុំយ៉ាងម៉េច ប្រជុំប៉ុន្មានថ្ងៃប្រជុំម្តង?

សឿនៈ បីថ្ងៃប្រជុំក្រុម រាល់ថ្ងៃប្រជុំពួក ល្ងាចឡើងប្រជុំជីវភាពរាល់តែថ្ងៃហ្នឹង ។

សុវណ្ណៈ	ចឹងប្រជុំរាល់ថ្ងៃ?

សឿនៈ	ចាស ។

សុវណ្ណៈ	ប្រជុំពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

សឿនៈ	ប្រជុំបីនាក់ពួកហ្នឹងតែមួយភ្លែត ប្រជុំក្រុមយូរដែរ ម៉ោង៧-៨ម៉ោង៩អីនោះបានឈប់ ។

សុវណ្ណៈ	ប្រជុំក្រុមប៉ុន្មានថ្ងៃប្រជុំម្ដង?

សឿនៈ	មានបីថ្ងៃ ។

សុវណ្ណៈ	ចឹងប្រជុំពួករាល់ថ្ងៃ?

សឿនៈ	ចាស ។

សុវណ្ណៈ	ប្រជុំពួកមានប៉ុន្មាននាក់ប្រជុំម្ដង?

សឿនៈ	បីនាក់ហ្នឹង ។

សុវណ្ណៈ	ចឹងប្រជុំក្រុមបីថ្ងៃម្ដង ហើយប្រជុំម្ដងមួយម៉ោងពីរម៉ោងទៅ?

សឿនៈ	ចាស!ជួនណាបីថ្ងៃដាក់ផែនការ យើងថាខ្ជិលគ្នាយើងចេះ យើងចាំមួយអាទិត្យអីទៅយើងចាំតែខាងលើពេក តែមានពិបាកអីដឹកប្រឡាយហ្នឹង យើងចង់ប្រជុំក៏អន្លុយប្រជុំទៅ ។

សុវណ្ណៈ	ហើយមួយក្រុមប្រជុំគ្នាប៉ុន្មាននាក់?

សឿនៈ	១២នាក់ ខ្លះនៅ១០ទៅខ្លះឈឺទៅដេកពេទ្យទៅមាន១០-១១ចឹងទៅ ។

សុវណ្ណៈ	ចឹងប្រជុំក្រុមចឹងអ៊ីជាអ្នកដឹកនាំប្រជុំ?

សឿនៈ	ចាស ។

សុវណ្ណៈ	ហើយអ៊ីប្រាប់គេយ៉ាងម៉េចខ្លះពេលប្រជុំម្ដងៗ?

សឿនៈ	ប្រជុំប្រាប់ថា ផែនការគេដាក់ហើយក្រុមយើងនេះមានប៉ុន្មានដូចថា ១០០ម៉ែត្រ២០០ម៉ែត្រ អាហ្នឹងភ្លឺស្រែ បើថាទំនប់ក្រុមយើងហ្នឹង២០ម៉ែត្រ ចឹងផែនការសម្រេចថា៧ថ្ងៃឬក៏កន្លះខែ ចឹងទៅហើយឬអត់ទេ យើងយ៉ាងម៉េចទេ ចេះតែគិតគ្នាធ្វើទៅបើអត់ហើយប្រឹងទៅ បើមិនហើយយើងមិនសូវហ៊ានឡើងទេ ។

សុវណ្ណៈ	ចឹងយើងមានដំណោះស្រាយឲ្យគ្នាខ្លះទេ ពេលគ្នាជួបបញ្ហារឿងការងារចឹង យើងមានដែលនិយាយប្រាប់ជាយោបល់ ថាធ្វើយ៉ាងនេះយ៉ាងនោះអី មានដែលប្រាប់គេខ្លះទេ?

សឿនៈ	ប្រាប់តើ ពេលជួបលំបាកចឹងយើងរាយការណ៍ទៅខាងលើទៅ ថាក្រុមខ្ញុំកន្លែងដីហ្នឹងមានថ្មរឹងអីចឹងទៅ បងខ្ញុំធ្វើមិនបានសម្រេចផែនការណ៍ទេ ចឹងខាងលើគេដើរមកមើលហើយ គេកន្លែងប្រឡោះខ្ញុំមាន១៥ទៅ២០ម៉ែត្រគេមកត្រួតពិនិត្យហើយ ឃើញជាក់ស្ដែងយើងធ្វើដែលចឹងទៅក៏អត់មានអីទេ ។

សុវណ្ណៈ	ចឹងប្រធានកងចល័តអីឈ្មោះអីគេ?

សឿនៈ	ឈ្មោះ ខន ។

សុវណ្ណៈ	ខន ហ្នឹងស្រីឬប្រុស?

សឿនៈ	ស្រី តើ ។

សុវណ្ណៈ	គាត់នៅស្រុកណាវិញ?

សឿនៈ	មិនដឹងជានៅណាទេ គាត់នៅខាងកណ្ដាលស្ទឹងអី ។

សុវណ្ណៈ	ម៉េចបានជាអ៊ំដឹងថា មកពីខាងកណ្ដាលស្ទឹង?

សឿនៈ	ខ្ញុំចេះតែឮគេៗដែលហ្នឹង ។

សុវណ្ណៈ	ចឹងគាត់អាយុដំណាលអ៊ំទេ ឬមួយចាស់ជាង?

សឿនៈ	បងខ្ញុំតើ កាលនោះ ។

សុវណ្ណៈ	គាត់អាយុប្រហែលជាប៉ុន្មាន?

សឿនៈ	អាយុ២០ជាងដឹង កាលនោះខ្ញុំនៅ១៧-១៨ឆ្នាំ គាត់២០ជាងហើយ ។

សុវណ្ណៈ	ហើយការគ្រប់គ្រងរបស់គាត់យ៉ាងម៉េចដែរ តឹងរឹងឬមួយមិនតឹងរឹងទេ?

សឿនៈ	មិនសូវអីទេ បើថាមានមិទ្ទីងចឹង ធ្វើពេលព្រឹកចឹងល្ងាចឡើងគាត់ឲ្យសម្រាកហើយ បើខ្លះគេមិនឲ្យសម្រាកទេ ដូចថាថ្ងៃហ្នឹងគេធ្វើមិទ្ទីងចឹង ល្ងាចហ្នឹងស្រួលគេទៅ ខ្លះធ្វើពេលព្រឹកចឹងហើយ ល្ងាចធ្វើម៉ោង៣ទៅម៉ោង៤បានឲ្យឈប់ កាលហ្នឹងដោយមេដែលហ្នឹង ។

សុវណ្ណៈ	ចឹងមិនសូវតឹងរឹងធ្វើបាបទេ?

សឿនៈ	ចាស!ដូចថាមិទ្ទីងព្រឹកហ្នឹងហើយ ល្ងាចគេឲ្យសម្រាកហើយ ពួកខ្ញុំដើរទៅកងគេនៅកាប់ដីចឹងទៅ មេគេវាងតឹងគេសម្រេចផែនការខាងលើនោះ ។

សុវណ្ណៈ	ចឹងអ៊ំយ៉ាងម៉េចបានជារើសអ៊ំឲ្យធ្វើប្រធានក្រុមកាលហ្នឹង?

សឿនៈ	ខ្ញុំនៅខាងខ្ញុំហ្នឹង គេហៅតំបន់១៥ហ្នឹង ដូចថាវាងគ្រោះគ្រាប់ផ្លោងយន្តហោះទម្លាក់អីក្ដួយវាលំបាក គេថាខ្ញុំខំតស៊ូគេឲ្យធ្វើទៅ ខ្ញុំមានចេះអីខ្ញុំ ។

សុវណ្ណៈ	ចឹងគណៈស្រុកឈ្មោះអីគេ កាលហ្នឹង?

សឿនៈ	គណៈស្រុក ។

សុវណ្ណៈ	គណៈស្រុកកន្លែងអ៊ំនៅធ្វើការហ្នឹង?

សឿនៈ	អត់ទេ ខ្ញុំស្គាល់តែឃុំ ស្រុកខ្ញុំមិនស្គាល់ទេ ។

សុវណ្ណៈ	កាលហ្នឹងអ៊ំនៅស្រុកណា?

សឿនៈ	កាលហ្នឹងខ្ញុំនៅកណ្ដាលស្ទឹងដែលហ្នឹង ។

សុវណ្ណៈ	ចឹងអ៊ំធ្វើខាងកងចល័តស្រុកហ្នឹងមកខាងកណ្ដាលស្ទឹងទេ?

សឿនៈ	ចាស!ខ្ញុំមកខាងត្បូងស្ទឹងនេះ ខ្ញុំមកនៅហ្នឹងឯង តាអោក តាមុន អីអ្នកខាងមន្ទីរស្រុកហ្នឹងដែរ មិនដឹងជាគាត់ទទួលខាងអី គាត់នៅខាងពាណិជ្ជកម្មអី ។

សុវណ្ណៈ	ចឹងអត់ស្គាល់គណៈស្រុកកណ្ដាលស្ទឹងទេ?

សឿនៈ	ចាស ។

សុវណ្ណៈ	ស្គាល់ត្រឹមឃុំ?

សឿនៈ	ត្រឹមឃុំ ។

សុវណ្ណៈ	គណៈឃុំអីគេ?

សឿនៈ	ឃុំពោធិ៍ឃុំហ្នឹង ។

សុវណ្ណៈ	ឃុំពោធិ៍ ស្រុកកណ្ដាលស្ទឹង?

សឿនៈ	ចាស ។

សុវណ្ណៈ	ភូមិអីគេ?

សឿនៈ	ខ្ញុំនៅភូមិហ្នឹង ឃុំហ្នឹង ។

សុវណ្ណៈ	ចឹងនៅកន្លែងកណ្ដាលស្ទឹងគេហៅតំបន់១៥?

សឿនៈ	ចាស ។

សុវណ្ណៈ	ម៉េចអ៊ំដឹងថាតំបន់១៥?

សឿនៈ	ចុះខ្មែរក្រហមគេដាក់ថាចឹង ខ្ញុំនៅក្មេងៗដែលចាស់គេហៅតំបន់១៥ ពេលទាហានដៀងមកគ្រាប់ធ្លាក់ចំភូមិ ហើយយន្តហោះអី ហើយទាហានពេលថ្ងៃចេះវាលួចទៅធ្វើការម្ដងៗដែរ ហើយខ្មែរក្រហមយើងក៏មកដែរ គេហៅតំបន់ប្រទាញប្រទង់ ភូមិខ្ញុំគ្មានបាននៅទេ ខ្ញុំនៅភូមិគេ ពេលខ្ញុំចេញ ចេញរហូតដល់សព្វថ្ងៃនេះឯង ។

សុវណ្ណៈ	ចឹងអ៊ំចេញពីភូមិនៅឆ្នាំ៧៦ទេ?

សឿនៈ	ខ្ញុំចេញពីភូមិតែម្ដងនៅឆ្នាំ៧៣ទេ ចេញមកនៅពោធិ៍ឃុំភូមិគេជិតៗ អត់មានបានមកចូលភូមិទេ ។

សុវណ្ណៈ	ចឹងបែកចេញពីឪពុកម្ដាយឆ្នាំណា បែកពីបងប្អូននោះ?

សឿនៈ	ខ្ញុំបែកពីឪពុកម្ដាយបងប្អូនខ្ញុំ ទើបបែកឆ្នាំ៧៥នេះ ។

សុវណ្ណៈ	ចឹង៧៣ចេញដែលតែនៅជាមួយឪពុកម្ដាយទេ?

សឿនៈ	ចាស!ខ្ញុំនៅជាមួយឪពុកម្ដាយខ្ញុំ ។

សុវណ្ណៈ	គ្រាន់តែខ្ញុំចេញទៅនោះបន្តិចចេញទៅនេះបន្តិច?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងដល់ឆ្នាំ៧៥ អ៊ីបែកពីឪពុកម្ដាយ ចេញទៅខាងកងចល័តបានបែកពីឪពុកម្ដាយតែម្ដងទៅ ទៅនៅជាមួយក្រុមកងចល័តមក?

សឿនៈ ចាស!ហ្នឹងហើយ ។

សុវណ្ណៈ ចឹងពេលបែកចេញពីឪពុកម្ដាយមានដែលនឹកនាទេ?

សឿនៈ នឹកតើ ។

សុវណ្ណៈ នឹកនាយើងធ្វើម៉េចទៅកាលហ្នឹង?

សឿនៈ កាលកងខ្ញុំផ្លាស់ទៅជិតកន្លែងម៉ែខ្ញុំស្ពានថ្មហ្នឹង យប់ឡើងខ្ញុំប្រាប់ប្រធានគេចឹងខ្ញុំទៅលេងមួយសន្ទុះចឹងទៅ យើងសុំក្នុងកងយើងកុំឲ្យមេកងធំគេដឹងទៅ ជួនកាលខ្ញុំមិនហ៊ានមកចឹងម៉ែខ្ញុំគាត់ទៅលេង ។

សុវណ្ណៈ ចឹងអ៊ីបន្ទាប់ពីចូលកងចល័តស្រុកហើយអ៊ីធ្វើអីទៀត?

សឿនៈ ខ្ញុំនៅបានមួយឆ្នាំឆ្នាំ៧៦-៧៧ខ្ញុំមក កាលពីដើមខ្ញុំមានគូរដណ្ដឹង គេដាក់ខ្ញុំមកគេធ្វើទ័ព ។

សុវណ្ណៈ ចឹង៧៧ចូលទ័ព?

សឿនៈ ចាស!មិនចូលប្ដីខ្ញុំគេធ្វើទ័ព ខ្ញុំមកតាម ។

សុវណ្ណៈ មកតាមគ្រួសារ?

សឿនៈ ចាស ។

សុវណ្ណៈ អ៊ីការឆ្នាំណា?

សឿនៈ ខ្ញុំឆ្នាំ៧៧ ការសម័យយើងកសាង សម័យចាប់ដៃគ្នា ។

សុវណ្ណៈ ចឹងការឆ្នាំ៧៧ ការជាមួយទាហាន?

សឿនៈ ការជាមួយយើងកងទ័ពហ្នឹង គ្រាន់ទៅអង្គុយគោរពទង់បក្សហ្នឹង គោរពទង់ជាតិអីចឹងទៅ ក្អួយគេឲ្យយើងប្ដេជ្ញាចិត្ត ។

សុវណ្ណៈ ចឹងពូស្រួយ ទ័ពពីមុនមកទេ?

សឿនៈ ខ្ញុំប្ដីខ្ញុំមួយហើយ គាត់ស្លាប់ឆ្នាំ៧៩ វាយយួននៅខាងបានលុង ។

សុវណ្ណៈ ចឹងគ្រួសារអ៊ីមុនគាត់ស្លាប់ឆ្នាំ៧៩ ទេ?

សឿនៈ គាត់ស្លាប់ឆ្នាំ៧៩ អេប្ដីខ្ញុំនេះមកស្លាប់ឆ្នាំ៨១ ហើយ ។

សុវណ្ណៈ ចឹងគ្រួសារមុនស្លាប់ឆ្នាំ៨១?

សឿនៈ ចាស!ស្លាប់និងយួនទាហាននេះណា ។

សុវណ្ណៈ ស្លាប់ពេលវាយជាមួយវៀតណាម?

សឿនៈ ចាស!ចូលទៅបន្ទាយពេលចេញមកជាន់មីនទាហានគេដាក់ ។

សុវណ្ណៈ នៅខាងណា?

សឿនៈ នៅខាង១០០១នោះ ។

សុវណ្ណៈ ចឹងពេលគ្រួសារក្រោយ ការនៅឆ្នាំណា?

សឿនៈ ឆ្នាំ៨៥-៨៦នេះហើយ ។

សុវណ្ណៈ ចឹងពូស្រួយនេះ ការឆ្នាំ៨៦ទេ?

សឿនៈ ចាស!ការ៨៥ឆ្នាំ៨៦ខ្ញុំបានកូនមួយហើយ ។

សុវណ្ណៈ ចឹងការឆ្នាំ៨៥?

សឿនៈ ចាស!ប្តីខ្ញុំស្លាប់តាំងពីឆ្នាំ៨១ ។

សុវណ្ណៈ ចឹងគ្រួសារមុនបានកូនប៉ុន្មាន?

សឿនៈ ខ្ញុំបានកូនមួយ ។

សុវណ្ណៈ ស្រីឬប្រុស?

សឿនៈ ប្រុស ។

សុវណ្ណៈ ចឹងពេលគ្រួសារក្រោយបានកូន៥នាក់?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងពេលការហ្នឹង?

សឿនៈ ការពេលហ្នឹង គ្មានសំអាងអីដែរ កាលហ្នឹងខ្ញុំនៅខ្មែរក្រហមដែរ ។

សុវណ្ណៈ កាលហ្នឹង រៀបការនៅណាវិញ?

សឿនៈ នៅ"គ៧"ដីថៃនោះ ។

សុវណ្ណៈ ចឹងឆ្នាំ៧៧ ការនៅណាវិញ?

សឿនៈ ខ្ញុំការនៅខាងខេត្តរតនគិរីនោះ ។

សុវណ្ណៈ ចឹង៧៧អឹចេញពីកណ្តាលស៊ឹងមកខេត្តរតនគិរី?

សឿនៈ ចាស!ខ្ញុំមកខែ៥ហើយ មើលចូលឆ្នាំហើយខ្ញុំមកហ្នឹង មកដល់ខែ៥បានខ្ញុំការ ខ្ញុំមកដល់ភ្នំពេញបានប្រហែលជាកន្លះខែបានគេយកមកវិនសៃហ្នឹងគេដឹកឡានមក គេដើរយកប្រវត្តិរូបអ្នកមានគ្រួសារអ្នកនៅលីវ អ្នកមានគូរដណ្តឹងអី គេជ្រើសរើសយកមកនោះ ពូៗមានប្រពន្ធគេដឹកយកមក ។

សុវណ្ណៈ កាលហ្នឹងតាមកងពលណា?

សឿន៖ កងពល៨០១ហ្នឹង តែខ្ញុំនៅ៨៣ កងពលតាសា រឿន ហ្នឹងឯង ខ្ញុំនៅតាម"វ"គេណា វរសេនាធំ៨៣ ។

សុវណ្ណៈ ចឹងគ្រួសារអ៊ីនៅវរសេនាធំ៨៣ទេ?

សឿន៖ គេហៅកងពល៨០១ ។

សុវណ្ណៈ កងពលបែកចែកចេញជាប៉ុន្មានវរៈ?

សឿន៖ ជាបី ។

សុវណ្ណៈ វរៈទី១ស្អីគេ?

សឿន៖ វរៈ៨១វរៈ៨២វរៈ៨៣ វរសេនាធំគេ ។

សុវណ្ណៈ ចឹងវរសេនាធំ៨១ វរៈ៨២ អ៊ីនៅ៨៣?

សឿន៖ ចាស ។

សុវណ្ណៈ ប្រធានវរៈសេនាធំ៨១ឈ្មោះអីគេ?

សឿន៖ ខ្ញុំអត់ស្គាល់ទេ ក្មួយ ។

សុវណ្ណៈ ទី២ឈ្មោះអីគេ?

សឿន៖ ខ្ញុំអត់ស្គាល់ទាំងអស់ ខ្ញុំដូចជាដំណើរកងចល័តដែរ កន្លែង៨០១ហ្នឹងដូចថា គ្នាច្រើនណាស់ គេយកមក ថាពីណានៅវរៈសេនាធំ៨១ គេទៅ៨១ពីណា៨២គេនៅ៨២ពីណា៨៣គេនៅ ៨៣ខ្ញុំនៅវរសេនាធំ៨៣ហ្នឹងឯង ។

សុវណ្ណៈ ចឹងនៅ៨៣វរសេនាធំពីណាគេ?

សឿន៖ តាប្រ៉ុ ហ្នឹងជនជាតិ ។

សុវណ្ណៈ ជនជាតិអីគេអ៊ី?

សឿន៖ ជនជាតិស្អីទេ គាត់អ្នកតស៊ូដែរ ។

សុវណ្ណៈ ជនជាតិទំពួនទេ?

សឿន៖ ចាស! បែបចឹងដឹង ។

សុវណ្ណៈ អត់ដឹងថាជនជាតិអីទេ?

សឿន៖ ចាស ។

សុវណ្ណៈ កងពល៨០១ប្រធានកងពលឈ្មោះអីគេ?

សឿន៖ តា០៥ហ្នឹង ។

សុវណ្ណៈ តា០៥?

សឿន៖ ប្រាប់ថា តាសា រឿន មិញហើយ ។

សុវណ្ណៈ	តាសួរ សឿន?
សឿនៈ	តាសួរ សឿន ហៅ០៥ ។
សុវណ្ណៈ	ម៉េចបានជាអ៊ីស្គាល់?
សឿនៈ	ខ្ញុំស្គាល់ពេលមកនៅនេះហើយ គាត់មកតាមកងអីហ្នឹង គាត់ដើរតា០៥ហ្នឹង ។
សុវណ្ណៈ	កាលហ្នឹងគ្រួសារអ៊ីធ្វើអីគេ?
សឿនៈ	គ្រួសារខ្ញុំធ្វើកងទ័ព ។
សុវណ្ណៈ	គេឲ្យកាន់ខាងណា?
សឿនៈ	កាន់ទាហានវរសេនាធំ៨៣ហ្នឹងឯង កងធំបីដែរ ។
សុវណ្ណៈ	ចឹងវរសេនាធំក្រោយមកគេបែងចែកជា?
សឿនៈ	ដូចថាមិនតាមវរៈបីវរសេនាតូចដែរ ។
សុវណ្ណៈ	ចឹងមានវរសេនាតូចទៀត?
សឿនៈ	ចាស!ហើយប្តីខ្ញុំហ្នឹងកងធំទៀត ។
សុវណ្ណៈ	កងធំអីគេ វរសេនាតូចអីគេ?
សឿនៈ	កងធំវរសេនាតូច៣១ ។
សុវណ្ណៈ	ហើយនៅក្នុងវរសេនា៨៣ហ្នឹង បែងចែកជាវរសេនាតូចប៉ុន្មាន?
សឿនៈ	បីវរៈដែលមាន៣១មាន៣២មាន៣៣ ប្តីខ្ញុំនៅ៣១ ។
សុវណ្ណៈ	ចឹងពេលវរសេនាធំ៨១បែងចែកជាប៉ុន្មានវរសេនាតូច?
សឿនៈ	ខ្ញុំមិនដឹងទេ ខ្ញុំមិនបានទៅកងវរៈគេដង ពីរវរៈទៀតខ្ញុំមិនដែលបានស្គាល់ទេ ។
សុវណ្ណៈ	តែគ្រួសារប្រធានវរសេនាតូច៣១?
សឿនៈ	៣១ ចាស ។
សុវណ្ណៈ	តែនៅក្នុងវរសេនាធំ៨៣នៅក្នុងកងពល៨០១?
សឿនៈ	ចាស!គាត់ស្លាប់បាត់ហើយ ។
សុវណ្ណៈ	ស្លាប់ពេលវាយជាមួយទាហានវៀតណាម?
សឿនៈ	ចាស!ទើបស្លាប់ឆ្នាំ៨០ឆ្នាំ៨១នេះហើយពេលឡើងមកលើភ្នំហ្នឹង?
សុវណ្ណៈ	វាយនៅខាងណា?
សឿនៈ	វាយនៅក្រខឹកក្របុំញនេះ ។
សុវណ្ណៈ	វាយនៅខាងណា?
សឿនៈ	វាយនៅ១០០១ហ្នឹង វាយនៅ១០០១ កាលហ្នឹងកូនខ្ញុំនៅតូច ។

សុវណ្ណៈ ចឹងទាហានវៀតណាមគេចូលវាយនៅរតនគិរីបាននៅពេលណា?

សឿនៈ ឆ្នាំ៧៩ ។

សុវណ្ណៈ ចឹងអ៊ីរត់ឆ្នាំណា?

សឿនៈ ចាស!ខ្ញុំរត់ឆ្នាំ៧៩ហ្នឹង ខែ១រត់មកនៅព្រៃរហូត ។

សុវណ្ណៈ រត់ទៅខាងណា?

សឿនៈ រត់ឡើងភ្នំហ្នឹង ព្រៃភ្នំចេះឯង ដល់ពេលឆ្នាំ៨០ហ្នឹង គេទាក់ទងតាមតាសា រឿន នេះឯង គេឲ្យឆ្លងទន្លេមេគង្គ ទន្លេសេកុងមកខាងដីថៃ ។

សុវណ្ណៈ ចឹងបានន័យថា ៧៩រត់ចូលព្រៃទេ?

សឿនៈ ចាស ។

សុវណ្ណៈ តែមិនបានដឹងថានៅណាទេ?

សឿនៈ មិនដឹងទេ នៅតែក្នុងព្រៃហ្នឹង គ្មានភូមិឃុំអីទេនោះ នៅតាមភ្នំ ។

សុវណ្ណៈ ចឹងពេលយើងរត់នៅក្នុងព្រៃយើងរស់យ៉ាងម៉េច យើងហូបយ៉ាងម៉េច?

សឿនៈ អាហ្នឹងបានយ៉ាប់ហូប ហូបតែក្តួចខ្ញុំមិនចេះហូបពុល ពុលឡើងស្គម ខ្ញុំមិនចេះហូបក្តួចអីទេ ដល់ពេលណាដំឡូងៗទៅ ដំឡូងមីយើងនោះ គេជម្លៀសមកព្រៃចេះមក ពូៗទៅស៊ើប ពេលណាអត់មានយួនទៅដក ដកយកមកឈូសធ្វើអង្ករដំឡូងចឹងទៅ ជួនណាយួនឡើងមក វាយចឹងទៅ ទៅភ្នំទៀតទៅជីកក្តួចស្ងោ ។

សុវណ្ណៈ ចឹងពេលទឹកបានមកពីណា?

សឿនៈ ទឹកតាមអូរភ្នំមិនចេះខ្វះទេ ទឹកទៅត្រង់ណាឃើញតែហូររហូតហ្នឹង ។

សុវណ្ណៈ ចឹងយប់ឡើងយើងគេងយ៉ាងម៉េច?

សឿនៈ ដេកតាមព្រៃហ្នឹង ហើយពេលណាអត់មានអង្រឹងពូៗហ្នឹងកាប់ឫស្សីស្រុកសម្បូរឫស្សីនោះ កាប់ធ្វើរានអីទៅដេកមួយយប់ពីរយប់ទៅទៀតហើយកាប់អីហ្នឹងទៀត ។

សុវណ្ណៈ ចឹងពេលភ្លៀង?

សឿនៈ ភ្លៀងមកប្រកបឫស្សីនិងពុះដាពីរដាក់ចឹងទៅ ដាក់តម្រៀបចេះគ្របវាពិបាកដែលហ្នឹង ។

សុវណ្ណៈ ហើយក្រោយមក មកនៅដល់ណា?

សឿនៈ ខ្ញុំក្រោយមកគេបានរយៈគេថាឲ្យឆ្លងទន្លេក៏មក ខ្ញុំមកនៅ១០០១ខាងទន្លេល្ពៅហ្នឹង ។

សុវណ្ណៈ ១០០១កាលហ្នឹងមកឆ្នាំណា?

សឿនៈ ខ្ញុំឡើងមកឆ្នាំ៨០ដល់៨៥ខ្ញុំរត់មកទៀត ។

សុវណ្ណៈ ១០០១គេហៅទន្លេអីគេ?

សឿនៈ ទន្លេល្ពៅ ។

សុវណ្ណៈ ម៉េចបានជាគេហៅទន្លេល្ពៅអ៊ី?

សឿនៈ មិនដឹងជាយ៉ាងម៉េច គេហៅជាទន្លេល្ពៅចេះតែហៅតាមគេទៅ ។

សុវណ្ណៈ ចឹងពេលមកដល់ហ្នឹងប្រហែលជាប៉ុន្មានខែបានយើងធ្វើដំណើរមកដល់ហ្នឹង?

សឿនៈ ខ្ញុំដេកផ្លូវប្រហែលជាមួយអាទិត្យជាង កាលនោះខ្ញុំមិនមានកូនចៅទេ កាលហ្នឹងខ្ញុំមកជិះទូក មកទាំងយប់ដើរទាំងយប់ហ្នឹងប្រហែលជា៨ទៅ៩ថ្ងៃខ្ញុំមកដល់លើភ្នំ មកដល់គេជួយឲ្យយើងបានអង្ករអីហូប ។

សុវណ្ណៈ ចឹងមកកន្លែង១០០១ហ្នឹង ពីណាជាអ្នកគ្រប់គ្រងកងពលណា?

សឿនៈ កងពល៨០១ដដែល ខ្ញុំនៅហ្នឹងរហូត ខ្ញុំទើបផ្តាច់ខ្លួនពេលចូលខេមរភូមិន្ទ ។

សុវណ្ណៈ ចឹងកងពល៨០១នៅក្នុងតំបន់១០០១?

សឿនៈ ចាស ។

សុវណ្ណៈ វរសេនាធំណា?

សឿនៈ ខ្ញុំនៅកន្លែង៨៣ដដែលហ្នឹង ។

សុវណ្ណៈ ចឹងតាសូរ សឿន គាត់នៅគ្រប់គ្រងនៅ១០០១ហ្នឹងដែរ?

សឿនៈ ចាស!នៅ១០០១ដែរ ហើយវរសេនាធំខ្ញុំ៨៣ហ្នឹងបែកបាក់ហើយ ខ្លះនៅខាងកើតទន្លេខ្លះឆ្លងមកខាងនេះទន្លេ ។

សុវណ្ណៈ ចឹង១០០១នៅណាអ៊ីចង្អុលមើល?

សឿនៈ នៅខាងនោះទេ ខាងកើតនោះ ។

សុវណ្ណៈ ចេញទៅពីហ្នឹងឆ្ងាយទេ?

សឿនៈ គេអ្នកនេះគេដែលទៅ ផ្លូវទាហាននៅឈរជើងនៅហ្នឹង ។

សុវណ្ណៈ ផ្លូវកន្លែងហ្នឹងគេហៅអីគេ?

សឿនៈ មិនដឹងជាហៅស្អីទេ ។

សុវណ្ណៈ ចឹងជុបរុនហ្នឹងកន្លែងអីគេ កន្លែងលេខប៉ុន្មាន១០០០ប៉ុន្មាន?

សឿនៈ កន្លែងជុបរុនកន្លែងពួកសឹករងតើ ។

សុវណ្ណៈ តែពីមុន១០០០ប៉ុន្មាន?

សឿនៈ ពីមុន១០០៣ ។

សុវណ្ណៈ ចឹងជុបរុន១០០៣?

សឿនៈ ចាស!ខ្ញុំនោះគេហៅ១០០១ ។

សុវណ្ណៈ	នៅ១០០១ហ្នឹងឥឡូវគេធ្វើស្អីវិញហើយ?

សឿនៈ	ឥឡូវមិនដឹងជាយ៉ាងម៉េច បើបែកមកយូរហើយ មិនដែលដឹងទេ តាំងពីចេញមក៨៥មក យួនវាយមកខ្ញុំរត់ចេញមករហូត ។

សុវណ្ណៈ	ចឹង១០០១ហ្នឹងនៅលើភ្នំដងរែក?

សឿនៈ	ចាស! នៅជាប់ដីថៃហ្នឹង ។

សុវណ្ណៈ	ឥឡូវមានដឹងថា១០០១ហ្នឹងទៅជាស្អីហើយនៅ?

សឿនៈ	មិនដឹងទេ តាំងពីហ្នឹងមករហូតមិនដែលបានទៅ ។

សុវណ្ណៈ	ហើយនៅលើភ្នំយើងរស់នៅបែបម៉េច លើ១០០១ហ្នឹង?

សឿនៈ	នៅហ្នឹងថៃ គេដឹកអង្ករបើកឲ្យហូប គេថាមួយអាទិត្យបើកឲ្យម្ដង ។

សុវណ្ណៈ	ក្រៅពីអង្ករគេមានបើកអីឲ្យផ្សេងទៀតទេ?

សឿនៈ	មានបើកត្រីខ បើកមី ជួនណាមានស្ករទឹកដោះគោ ។

សុវណ្ណៈ	របបគេបើករបៀបយ៉ាងម៉េចអ៊ំ?

សឿនៈ	បើកមនុស្សចាស់ចឹងឲ្យពីរកំប៉ុង ហើយក្មេងរៀងទ្រឹសចាប់ពី៥ឆ្នាំឡើងមួយកំប៉ុងកន្លះ ។

សុវណ្ណៈ	សម្រាប់មួយថ្ងៃឬយ៉ាងម៉េច?

សឿនៈ	ចាស! សម្រាប់មួយថ្ងៃ បើអ្នកតូចៗគេឲ្យមួយកំប៉ុង ។

សុវណ្ណៈ	ចឹងក្រៅពីអង្ករគេមានបើកអីផ្សេងឲ្យទេ?

សឿនៈ	បើកឲ្យតើ ឲ្យត្រីខ ឲ្យស្ករ មានប៊ីចេង ពេលយើងមករស់នៅលើដីថៃហ្នឹង ជួនណាមួយអាទិត្យជួនណា១០ថ្ងៃ ជួនណាបារាំងគេមកយើងទៅគេបើកបន្លែចឹងទៅ ។

សុវណ្ណៈ	ចឹងមួយអាទិត្យឬ១០បានគេបើក?

សឿនៈ	ចាស! បើកមីអី ត្រីខ អីហ្នឹងគេបើកទូទៅ បើអង្ករបានមានរបប ។

សុវណ្ណៈ	អង្ករគេបើករបៀបយ៉ាងម៉េច?

សឿនៈ	ជួនណាអង្ករមកច្រើនគេឲ្យមួយអាទិត្យម្ដង ជួន៥ថ្ងៃទៅ បើអង្ករបានមករៀងច្រើនចឹងគេបើក១០ថ្ងៃម្ដងចឹងទៅ ម្នាក់ពីរកំប៉ុងយើងគិតតាមហ្នឹងចឹងទៅ ។

សុវណ្ណៈ	ខាងណាគេអ្នកបើកឲ្យខ្មែរអ្នកបើកឲ្យ?

សឿនៈ	ខ្មែរយើងហ្នឹង កងយើងចឹងហ្នឹង គេមានសេដ្ឋកិច្ចសម្រាប់បើកឲ្យយើង ។

សុវណ្ណៈ	ចឹងរបស់អស់ហ្នឹងគេដឹកមកពីណា?

សឿនៈ	មកពីថៃមក ។

សុវណ្ណៈ	ហើយខាងណាអ្នកជួយ?

សឿនៈ មិនដឹងជាខាងណាទេ ។

សុវណ្ណៈ ជំនួយខាងណាអ្នកជួយដឹងទេ?

សឿនៈ ខាងណាទេ ខ្ញុំមិនដឹង ខ្ញុំដឹងថាមកពីថៃ ។

សុវណ្ណៈ ចឹងយើងមានរកស៊ីអីដោះដូរជាមួយថៃទេ?

សឿនៈ រកដែលគេ អ្នករកគឺរក ខ្ញុំអីហ្នឹងប្រូតស្បៅក្រងលក់ឲ្យថៃ ខ្លះគេអ្នកបេះរក រកស៊ីជាមួយថៃ រកធ្វើការឲ្យថៃ ប្ដីខ្ញុំណានៅមុខដែរ មិនសូវបានមកផង ខ្លះដុតធ្យូងលក់ឲ្យថៃមួយបាវធ្លូតចឹង២៥បាត ។

សុវណ្ណៈ ចឹងមានរកស៊ីអីធំៗជាមួយថៃទេ?

សឿនៈ អត់ទេ ខ្ញុំមិនដែលទេ គេអ្នកហ៊ានរកគេរក ពួកខ្ញុំនេះមិនដែលរកអីទេ ។

សុវណ្ណៈ និយាយខាងទាហានអី គេមានរកស៊ីធំៗជាមួយថៃទេ?

សឿនៈ ទាហានអត់មានមកពាក់ពិនទេ ទាហាននៅតែ១០០១ទេ គេឲ្យវាយ មានតែអ្នកពិការជរាអី គេឲ្យនៅកម្លាំងខាងក្រោយបានមាន ។

សុវណ្ណៈ ខ្ញុំចង់និយាយថា មេៗធំៗរបស់គេ មេធំៗគេមានរកស៊ីឈើរកស៊ីវត្ថុបុរាណជាមួយថៃទេកាលហ្នឹង?

សឿនៈ ខ្ញុំនៅ១០០១ហ្នឹង?

សុវណ្ណៈ បាទ ។

សឿនៈ អត់មានឈើមានអីទេ បើនៅនេះមាន ។

សុវណ្ណៈ ចង់និយាយថា ពីមុនមកអឺនៅ១០០១?

សឿនៈ ពីមុនមកអត់ទេ បើវត្ថុបុរាណអីហ្នឹង ខ្ញុំមិនបានដឹងទេ របស់មើលមិនឃើញ ។

សុវណ្ណៈ ចឹងអត់មានដឹងថា គេរកស៊ីឈើជាមួយថៃ ដឹកវត្ថុបុរាណទៅថៃអីកាលហ្នឹងមានទេ?

សឿនៈ អត់មានដឹងទេ បើអ្នកបានភ្លុកដំរីមាន គេយកទៅលក់ឲ្យថៃ ។

សុវណ្ណៈ ចឹងអាហ្នឹងសម្រាប់ប្រជាជនយើងធម្មតាទេ គេរកស៊ីចឹង?

សឿនៈ ចាស!ប្រជាជនយើងធម្មតាទេ អ្នកធំខ្ញុំមិនបានដឹងទេ បើនៅនេះអ្នកធំចេញឈើឲ្យថៃ ។

សុវណ្ណៈ អាហ្នឹងបច្ចុប្បន្ននេះទេ?

សឿនៈ បច្ចុប្បន្នស្អីតាំងពីនៅជិនាន់តាម៉ុក នោះ ខ្ញុំមកនៅនេះតាំងពី៨១ចឹង ៨៥ខ្ញុំចេញមក ខ្ញុំមករហូត ។

សុវណ្ណៈ ចឹងកាលនៅ១០០១ហ្នឹងគេមានរកស៊ីកាប់ឈើលក់ឲ្យថៃដែលកាលហ្នឹង?

សឿនៈ អត់ទេ មិនដែលទេ ឈើនៅពេញព្រៃហ្នឹងមិនដែលមានពីណាកាប់ទេ ថៃមិនដែលចេញចូលមកយើងដែរ មកតាមរយៈគេដឹកអង្ករឲ្យមកទេ ។

សុវណ្ណៈ ចឹងអាវុធអីគេមានដឹកមកទេ អាវុធសម្រាប់ទ័ពអីនោះ កាំភ្លើង?

សឿនៈ មានតើ មានឃ្លាំងក្រោយ តែខ្ញុំមិនដែលបានទៅជិតផងហ្នឹង ឃ្លាំងគេក្រោយដឹកមកឲ្យទាហានដឹកមកចឹង ក្រោយជិតដីថៃដែរ ឃ្លាំងគេធ្វើ ។

សុវណ្ណៈ ឆ្នាំណាអ៊ីចេញពី១០០១?

សឿនៈ ឆ្នាំ៨៥ ។

សុវណ្ណៈ ហើយមានមូលហេតុអីចេញពី១០០១?

សឿនៈ យួនវាយចូលមក យើងទប់មិនឈ្នះកាលហ្នឹង ជម្លៀសប្រជាជនមក ។

សុវណ្ណៈ កាលហ្នឹងគេវាយយ៉ាងម៉េចអ៊ី ខាងវៀតណាម?

សឿនៈ គេវាយទៅដល់ព្រំដែនថៃនោះ ដល់ចឹងពួកខ្ញុំគេជម្លៀសមកចូលដីថៃ ហើយនៅហ្នឹងពិបាកទប់ទ័ព គេដឹកពួកខ្ញុំពី១០០១ដាក់នៅ១០០៣ ។

សុវណ្ណៈ ចឹងអ៊ីចេញពី១០០១ទៅណាទៅ១០០៣?

សឿនៈ ចាស! ចេញពី១០០១មកនៅជាមួយពួក១០០៣ ។

សុវណ្ណៈ ១០០៣នៅខាងណាវិញ?

សឿនៈ នៅតាមនេះឯងនៅតាមអូរត្រាវ នៅកន្លែងអស់ហ្នឹងគេហៅតំបន់គេ ខ្ញុំកាលហ្នឹងនៅអូរធំនោះ គេប្រមូលមកនេះខ្ញុំមកនៅហ្នឹងឯង ដល់ឆ្នាំប៉ុន្មានទេ ឆ្នាំ៩៣-៩៤ហើយខ្ញុំរត់ទៅអូរស្វាយវិញ ។

សុវណ្ណៈ ចឹងអ៊ី៨៥អ៊ីចេញពី១០០១ទៅ១០០៣?

សឿនៈ ចាស ។

សុវណ្ណៈ ហើយ១០០៣ហ្នឹងពីណាគេគ្រប់គ្រង?

សឿនៈ តា០៥ហ្នឹងហើយ គាត់អ្នកជម្លៀសទៅ មានយើងរត់ទៅនេះណា ។

សុវណ្ណៈ ខាងទ័ពគេនាំទៅ?

សឿនៈ ចាស! ទ័ពគេដឹកនាំមីងៗទៅគេទុកប្ដីៗឲ្យនៅវាយ ។

សុវណ្ណៈ ចឹងនៅ១០០១ហ្នឹងធ្វើអីគេខ្លះ មានចូលកងដឹកជញ្ជូនអីគេទេ?

សឿនៈ អត់ទេ បានកូនហើយកាលនោះ ។

សុវណ្ណៈ ចឹងមានចាក់ចំរូងអីទេ?

សឿនៈ កាលខ្ញុំជម្លៀសពី១០០១ទន្លេល្អាបិតចំបូង ខ្ញុំទូចំបូងទៅមុខដែលតើ តែទៅពីព្រឹកចឹងល្ងាចមកវិញ យើងមានកូន ។

សុវណ្ណៈ ចឹងទៅកាប់ឫស្សីយកមកធ្វើនៅផ្ទះមក?

សឿនៈ ចាស ។

សុវណ្ណៈ ហើយមួយថ្ងៃគេឲ្យធ្វើប៉ុន្មាន គេមានកំណត់យើងទេ?

សឿនៈ គេកំណត់ដែលតើ១០០ជួនកាលឲ្យបាន២០០ទៅ៣០០ធ្វើមិនបានក៏អត់មានអីមីងៗបើមិនចេះបិតផង ខ្ញុំកាលហ្នឹងខ្ញុំបានប្តីចឹងគេអត់មានឲ្យទៅមុខទេ គ្រាន់ទូលចំបូងទៅព្រឹកចឹងទៅល្ងាចមកវិញ ខ្លះថ្ងៃម៉ោង១១មកដល់ ។

សុវណ្ណៈ ចឹងយើងទូលចំបូងឲ្យគេ យកឲ្យទ័ព?

សឿនៈ យកទៅដាក់កន្លែងស្នាក់ការគេ គ្រាន់ជញ្ជូនចុះពីភ្នំទៅដល់ដាក់ អ្នកកូនធំៗហើយបើមានកូនតូចគេឲ្យនៅផ្ទះឲ្យបិតចំបូងអី ។

សុវណ្ណៈ ចំបូងមានប៉ុន្មានប្រភេទ?

សឿនៈ បើខាងខ្ញុំមិនដែលធ្វើចំបូងក្រញែសក្រញាស់ទេ បិតតែចំបូងធម្មតាហ្នឹង បើពូៗគេឲ្យធ្វើចំបូងបោះទៅក្រញាស់ បើខ្ញុំអត់ទេ មីងៗបិតក្បាលបិតកន្ទុយនិងឯង ។

សុវណ្ណៈ ចឹងពេលយើងមក១០០៣យើងធ្វើអីវិញ?

សឿនៈ អត់មានបានធ្វើអីទេ នៅហ្នឹងនៅតែផ្ទះ ហើយទ័ពនៅនោះទៅមានបានបិតចំបូងអីណា ។

សុវណ្ណៈ ចឹងអត់មានជញ្ជូនគ្រាប់អីគេទេ?

សឿនៈ ចាស!មានកងគេអ្នកដែលនៅលីវគេឲ្យជញ្ជូន ។

សុវណ្ណៈ ពេលមីងមានគ្រួសារគេឲ្យធ្វើអីគេវិញ?

សឿនៈ មានគ្រួសារកូនចៅគេឲ្យនៅផ្ទះហ្នឹងឯង គ្រៀមខ្លាចគេផ្អើលគេរត់អីហ្នឹង ទៅដីថៃ មុនដំបូងគេមិនទាន់ឲ្យចូលដីថៃទេ នៅព្រំដែនវាយៗចេះតែសម្រុកចូលជិតថៃ ។

សុវណ្ណៈ ចឹងពេលមកផ្ទះចឹង មានធ្វើចំបូងអីដែរ?

សឿនៈ អត់ទេ កាលនៅដីថៃអត់មានធ្វើអីផង គេបើកអង្ករឲ្យហូបមិនដែលធ្វើអីទេ គេនៅទន្លេល្អាអីបានធ្វើ ។

សុវណ្ណៈ ចឹងមានរកស៊ីអីជាមួយថៃទេ មានធ្វើការអីឲ្យថៃទេ កាលមក១០០៣ហ្នឹង?

សឿនៈ មិនដែលទេ ខ្ញុំមានប្រូតស្បូវអីដែរ ក្រងលក់តាមធម្មតាចឹង បើនៅ១០០១ហ្នឹងមិនដែលរកអីសោះ ។

សុវណ្ណៈ ចឹងឆ្នាំណាយើងចុះមកក្រោម ចុះមកដល់ដំបូង ចុះពីភ្នំដងរែកមក៩០ប៉ុន្មាន?

សឿនៈ ៩០ប៉ុន្មានទេ ។

សុវណ្ណៈ ៩០គត់?

សឿនៈ ៩០គត់ដឹង ។

សុវណ្ណៈ ព្រោះឆ្នាំ៩០ ខ្មែរក្រហមវាយបានអន្លង់វែង?

សឿនៈ ហ្នឹងហើយមួយសារហ្នឹង ខ្ញុំចុះមកនៅនោះ មើលខ្ញុំគិតសិនកូនខ្ញុំកើត៨៩ ឆ្នាំ៩០អីហ្នឹង ឯងខ្ញុំមកហ្នឹង ព្រោះកូនខ្ញុំអាបងនោះវាកើត៨៩ ។

សុវណ្ណៈ ចឹង៩០ ?

សឿនៈ ចាស!ចុះមកនៅខាងជាំនោះ ខាងស្រះឈូក ។

សុវណ្ណៈ ចឹងចុះមកដល់ដំបូងមកនៅស្រះឈូក?

សឿនៈ ចាស!នៅស្រះឈូកតែពួកកងខ្ញុំនៅអូរជីកនេះទេ តែខ្ញុំស្នាក់នៅហ្នឹងពីរបីថ្ងៃ ពួកខ្ញុំនៅអូរជីកនេះ ។

សុវណ្ណៈ ចឹងកងរបស់អ៊ំនៅខាងអូរជីកទេ?

សឿនៈ ចាស!ខ្ញុំដេកនៅហ្នឹង ។

សុវណ្ណៈ តែអ៊ំមកនៅស្រះឈូក?

សឿនៈ ចាស!វាទឹកពេកនៅបានបួនដប់ថ្ងៃបានមកកន្លែងនេះវិញ ។

សុវណ្ណៈ ចឹងក្រោយមក មកនៅណាទៀត?

សឿនៈ មកនៅអូរជីកនេះ ។

សុវណ្ណៈ ចឹងកាលហ្នឹងមកនៅធ្វើអីគេ?

សឿនៈ មកនៅកាប់ចម្ការដែលហ្នឹង កាលហ្នឹងអត់មានធ្វើអីទេ តែគេនៅបើកអង្ករឲ្យហូប គេឲ្យយើងធ្វើចម្ការដូចថា យើងធ្វើចម្ការហូបខ្លួនឯងហ្នឹងណា តែកាលនោះនៅបើកអង្ករឲ្យ ។

សុវណ្ណៈ ហើយចុះកាលហ្នឹងពីណាគេគ្រប់គ្រង?

សឿនៈ មានពីណា តាសា រឿន ហ្នឹង ។

សុវណ្ណៈ ចឹងមិនមែនតាម៉ុកទេ?

សឿនៈ តាម៉ុក គាត់លើតាសា រឿន ហ្នឹងទៀត ។

សុវណ្ណៈ ចឹងតាម៉ុក គាត់គ្រប់គ្រងធំទាំងអស់តែម្តង?

សឿនៈ ចាស!ធំហើយ តាម៉ុក លើតាសា រឿន ទៀត ។

សុវណ្ណៈ អ៊ំមានដែលបានជួបតាម៉ុក ទេ?

សឿនៈ ខ្ញុំមិនដែលបានស្គាល់ទេ ខ្ញុំឮតែឈ្មោះទេ ខ្ញុំមិនដែលឃើញមុខតាម៉ុក ទេ ។

សុវណ្ណៈ ចឹងអ៊ីដែលបានជួបតាម៉ុក ដែរ?

សឿនៈ អត់ទេ ខ្ញុំមិនដែលបានជួបសោះ ។

សុវណ្ណៈ ចឹងតាម៉ុក នៅអូរជីកដែលតើ ម៉េចបានជាមិនដែលជួបគ្នាចឹង?

សឿនៈ អូរជីកតែអូរជីកតាម៉ុក នោះ ខ្ញុំនៅអូរជីកខាងក្រោមនោះគ្រាន់ឈ្មោះអូរជីកតែមួយ ។

សុវណ្ណៈ អូរជីកណាវិញ?

សឿនៈ តាម៉ុក អូរជីកជិតជាំណាស់ ខ្ញុំអូរជីកដែលតែខាងក្រោមនេះទៅ ។

សុវណ្ណៈ អូរជីកមកខាងត្រពាំងប្រាសាទវិញ?

សឿនៈ ចាស ។

សុវណ្ណៈ មានអូរជីកមួយទៀត?

សឿនៈ ខ្ញុំនៅអូរជីកកន្លែងពួកភូមិតាមែននេះ ។

សុវណ្ណៈ អ៊ីងដិបូងចុះមកតាមណា?

សឿនៈ ខ្ញុំមកតាមនេះ តាមស្រះឈូកមកភូមិស្អី តាមរវៀងនេះពួក១០៥នេះ ។

សុវណ្ណៈ ចឹងមកតាមភូមិ១០៥?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងមកតាមផ្លូវ?

សឿនៈ ចាស!មកហ្នឹងទេ ។

សុវណ្ណៈ ចឹងចុះមកដិបូងចុះមកនៅផ្លូវសិនតើអី?

សឿនៈ ចាស!ខ្ញុំដេកនៅស្រះឈូកបានបីយប់ បានខ្ញុំមកទៀតមក មកខាងរវៀងនេះ ។

សុវណ្ណៈ រវៀងខាងរតនគិរី?

សឿនៈ អត់ទេ នេះអ្នករវៀងភូមិរវៀងនេះ ។

សុវណ្ណៈ ចឹងមកតាមភូមិរវៀងនេះទេ?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងភូមិរវៀងនៅក្នុងស្រុកត្រពាំងប្រាសាទដដែល?

សឿនៈ នៅស្រុកអន្លង់វែងទេ ឥឡូវនេះ មកតាមរវៀងហ្នឹងបានមកនៅអូរជីកក្រោមនេះ អូរជីកតាម៉ុក ឆ្ងាយណាស់ ។

សុវណ្ណៈ ខ្ញុំស្មានអូរជីកនៅជាំ?

សឿនៈ អត់ទេ អូរជីកនៅក្រោមនេះ ។

សុវណ្ណៈ ចឹងចុះមកដល់ដំបូងមកនៅត្រពាំងប្រាសាទនេះតែម្ដង មកនៅស្រុកត្រពាំងប្រាសាទនេះ ចុះមកដល់ដំបូង ចឹងស្រះឈូកនៅជិតជាំ?

សឿនៈ ចាស ។

សុវណ្ណៈ ហើយក្រោយមកបានប្ដូរដប់ថ្ងៃ យើងផ្លាស់មកនៅស្រុកខាងត្រពាំងប្រាសាទ ម្ដុំត្រពាំងប្រាសាទនេះ?

សឿនៈ ចាស ។

សុវណ្ណៈ អូរជីកឥឡូវគេហៅភូមិអីគេ?

សឿនៈ មិនដឹងយ៉ាងម៉េចឥឡូវ តែពីមុនអូរជីក អូរស្មាយនេះ ឥឡូវឃុំអូរស្មាយនេះ តែខាងនោះអូរស្មាយខ្ញុំនៅ ខាងត្បូងអូរស្មាយទៀតគេហៅអូរជីក ។

សុវណ្ណៈ ចឹងក្រោយមកចុះមកនៅអូរស្មាយទេ?

សឿនៈ ចាស!អូរស្មាយ អូរជីកហ្នឹង ឥឡូវឃុំអូរស្មាយនៅដែលតើ និយាយរួមដាក់អូរស្មាយទៅ មិនបាច់ដាក់អូរជីកទេ អូរជីកយើងហៅធម្មតា ។

សុវណ្ណៈ ខ្ញុំខ្លាចច្រឡំអូរជីកនៅខាងជាំ?

សឿនៈ ចាស ។

សុវណ្ណៈ ម៉េចបានជាគេដាក់ថាអូរស្មាយ?

សឿនៈ មិនដឹងជាយ៉ាងម៉េច ជម្លៀសទៅគេដាក់ថាអូរស្មាយ ។

សុវណ្ណៈ ចឹងកន្លែងហ្នឹងសុទ្ធតែព្រៃទេ មានអូរមកពីណា?

សឿនៈ មានតែអូរមានភូមិប្រជាជនឯណា គេចេះតែដាក់ទៅ មើលពួកខ្ញុំពួកអូរស្មាយ ហើយពួកខាងនោះគេហៅពួក១៧ពួក៨០០អ្នកខាងលើគេដាក់ចឹង ។

សុវណ្ណៈ អីរត់ម្ដងទៀតពេលណាទៅ បន្ទាប់ពីចុះមកនៅក្រោម?

សឿនៈ រត់ពីអូរស្មាយមក នៅនេះឯង ។

សុវណ្ណៈ រត់ពីអូរស្មាយរត់ឆ្នាំណា?

សឿនៈ រត់ឆ្នាំ៩៦អី ៩៦-៩៧ហើយដឹង យើងផ្ដាច់ខ្លួនមកនេះបណ្ដោយ ។

សុវណ្ណៈ រត់មុនសមាហរណ៍កម្មឬរត់ក្រោយសមាហរណ៍កម្ម ព្រោះសមាហរណ៍កម្មឆ្នាំ៩៨?

សឿនៈ អ៊ូ!មួយសារហ្នឹងឯង ។

សុវណ្ណៈ មុនសមាហរណ៍កម្ម?

សឿនៈ ចាស!គេសមាហរណ៍កម្មហើយខ្ញុំមកនេះ ។

សុវណ្ណៈ ចឹងយើងមានរត់ម្ដងទៀត ព្រោះថាឆ្នាំ៩០ដដែលហ្នឹងក៏ខាងរដ្ឋាភិបាលវាយយកអន្លង់វែងវិញ?

សឿនៈ ចាស ។

សុវណ្ណៈ អឺមានរត់ទៀតទេ?

សឿនៈ អាហ្នឹងខ្ញុំមកនៅនេះ ខ្ញុំមកពីរអូរធំមក មកពីអូរជីកវិញមកនៅនេះ មកនៅនេះហើយឆ្នាំ៩៨អីហ្នឹង ខ្ញុំរត់ទៅអូរស្មាយហ្នឹង ដល់ពេលរដ្ឋាភិបាលផ្ដាច់ខ្លួនបានរត់មកនេះវិញ ។

សុវណ្ណៈ ចឹងចុះមកដល់ដំបូងមកនៅម្ដុំស្រះឈូកសិន?

សឿនៈ ចាស ។

សុវណ្ណៈ បន្ទាប់មកគេវាយអីយើងរត់ទៅណាទៀតឆ្នាំ៩០ប៉ុន្មាន?

សឿនៈ ខ្ញុំនៅអត់បានគេវាយទេ កាលខ្ញុំនៅស្រះឈូកហ្នឹង នៅសម្រាកបានពីរបីថ្ងៃហ្នឹង ខ្ញុំមកនៅភូមិអូរជីកនេះ ដាក់ថាអូរស្មាយទៅខ្ញុំមកនៅហ្នឹងឯង ។

សុវណ្ណៈ ចឹងអឺថា រត់អីម្ដងទៀតនោះ មុនរត់មកអូរស្មាយសិន?

សឿនៈ អាហ្នឹងរត់ពួកយើងវាយនេះ ខ្ញុំមកពីហ្នឹងមកនៅអូរស្មាយហ្នឹង ចុះពីស្រះឈូកមកនៅបានប៉ុន្មាន មកនៅគេហៅអូរធំ ។

សុវណ្ណៈ ចឹងមកនៅអូរធំសិន?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងមកនៅអូរធំ?

សឿនៈ ចាស!មកនៅអូរធំមុនមកនៅអូរស្មាយ នៅអូរធំគា០៥ហ្នឹងយកពួកខ្ញុំមកនៅនេះ ។

សុវណ្ណៈ ចឹងអូរធំហើយបានអូរស្មាយ?

សឿនៈ ចាស!អត់ទេ អូរធំហើយមកនៅត្រង់នេះ នៅទំនប់ដាច់ ។

សុវណ្ណៈ មកនៅទំនប់ដាច់សិន?

សឿនៈ ចាស!ទំនប់ដាច់ហើយ ។

សុវណ្ណៈ ចឹងនៅបានប៉ុន្មានខែប៉ុន្មានឆ្នាំមកនៅអូរធំហ្នឹង?

សឿនៈ ប៉ុន្មានឆ្នាំដែលហ្នឹង នៅទំនប់ដាច់នេះ ខ្ញុំនៅអូរធំបានប្រហែលពីរឆ្នាំហ្នឹងឯងបានគា០៥យកមកនៅនេះ ។

សុវណ្ណៈ ចឹងនៅអូរធំបានប្រហែលជាពីរបីឆ្នាំ?

សឿនៈ ចាស!អាចពីរឆ្នាំអីប៉ុណ្ណឹងទេ ។

សុវណ្ណៈ ចឹងនៅហ្នឹងស្រួលទេអត់មានទាហានខាងរដ្ឋាភិបាលគេវាយទេ?

សឿនៈ ចាស ។

សុវណ្ណៈ គេវាយតែខាងអន្លង់វែងទេ នៅនេះគេវាយមិនដល់ទេ?

សឿនៈ អត់ទាន់វាយទេ ជំនាន់នោះ ជំនាន់អ៊ុនតាក់ជឹង មិនទាន់បានវាយទេ ដល់ហើយឆ្នាំ៩១-៩២ហ្នឹងយកតា០៥មកនៅនេះ ។

សុវណ្ណៈ ចឹងប្រហែលជាឆ្នាំ៩១-៩២ចេញពីអូរធំមកនៅខាងទំនប់ដាច់?

សឿនៈ មកនៅនេះ ដល់ឆ្នាំ៩៣-៩៤បានខ្ញុំចេញពីនេះទៅអូរស្មាយវាយគ្នាហើយ វាយចេញពីភូមិកន្ទួតអីហ្នឹងមក ។

សុវណ្ណៈ ចឹងដល់ពេល៩៣-៩៤យើងចេញពីទំនប់ដាច់ទៅអូរស្មាយវិញ?

សឿនៈ ចាស ។

សុវណ្ណៈ ដោយសារមានខាងរដ្ឋាភិបាលគេវាយ?

សឿនៈ ចាស ។

សុវណ្ណៈ គេវាយចេញពីណាមកវិញ?

សឿនៈ វាយមកពីខាងកន្ទួតហ្នឹងឯងរថក្រោះអី មុនដុះតា០៥តាមហ្នឹងធំៗណាស់ ។

សុវណ្ណៈ វាយចេញពីខាងព្រះវិហារមកវិញ?

សឿនៈ ចាស!ហ្នឹងហើយ វាយចេញពីខាងព្រះវិហារមកសុទ្ធតែរថក្រោះអីមកវាយ ។

សុវណ្ណៈ វាយតាមច្រកណា?

សឿនៈ តាមផ្លូវយើងនេះ កាលហ្នឹងមានផ្លូវជាតិណាផ្លូវដើងហ្នឹង ភូមិកន្ទួត ភូមិសាអែមនេះ ។

សុវណ្ណៈ វាយចេញពីសាអែមមកវិញ?

សឿនៈ ចាស ។

សុវណ្ណៈ ហើយរត់ទៅអូរស្មាយ?

សឿនៈ ចាស!ខ្ញុំជម្លៀសទៅនៅអូរស្មាយ ។

សុវណ្ណៈ ទៅនៅអូរស្មាយបានប៉ុន្មានខែប៉ុន្មានឆ្នាំបានមកវិញ?

សឿនៈ អាហ្នឹងបានយូរបានពីរបីឆ្នាំហើយដឹង តាំងពីហ្នឹងមកទើបមកនៅនេះតើ ។

សុវណ្ណៈ ចឹងមកនៅអូរស្មាយហ្នឹងពេលចុះចូលជាមួយរដ្ឋាភិបាលទេ?

សឿនៈ អត់ទាន់ទេ មុនមិនទាន់ទេ ចុះចូលមកនៅនេះឯង ។

សុវណ្ណៈ ចង់និយាយថា ត្រឡប់ពីអូរស្មាយមកនៅទំនប់ដាច់វិញ?

សឿនៈ អាហ្នឹងចុះចូលហើយ ។

សុវណ្ណៈ ចឹងសមាហរណ៍កម្មហើយ?

សឿនៈ ចាស!គេជម្លៀសដូចថា ទ័ពរដ្ឋាភិបាលយើងឡើងទៅគេជម្លៀសប្រជាជនអ្នកដែលគេមិនចង់ចូលមកជាមួយរដ្ឋាភិបាលគេទៅខាងតាម៉ុក ខ្ញុំមកខាងនេះបណ្តោយមក ។

សុវណ្ណៈ ចឹងមកមុន?

សឿនៈ ចាស!ពួកភូមិខ្ញុំ ពួកទ័ពៗផ្តាច់ខ្លួនចូល កាលហ្នឹងដូចទៅយកប្រពន្ធកូនមានអ្នកដូចថារាប់អានគ្នាណាជិតស្និតដែលតានោះក៏ខ្ញុំមកតាមគាត់មក ។

សុវណ្ណៈ ផ្តាច់ខ្លួនមុនហ្នឹងឆ្នាំណា?

សឿនៈ ក្នុងខែដែលហ្នឹងមកជាមួយគ្នាដែលហ្នឹង គ្រាន់មុនបន្តិចចឹងទៅណាស់ ។

សុវណ្ណៈ ចឹង៩៨ដដែលទេ?

សឿនៈ ចាស ។

សុវណ្ណៈ ចឹងអឹជីងទេ គេធ្វើសមាហរណ៍កម្មឆ្នាំណា?

សឿនៈ ដឹងឆ្នាំណា ក្រែងឆ្នាំ៩៨ហ្នឹងដឹង ។

សុវណ្ណៈ ចុងឆ្នាំឬពាក់កណ្តាលឆ្នាំ ឆ្នាំ៩៨ហ្នឹង?

សឿនៈ ចុងដឹង ។

សុវណ្ណៈ ចឹងអឹមកមុនបានមួយខែបានធ្វើសមាហរណ៍កម្ម?

សឿនៈ មកនៅនេះបានប៉ុន្មានខែដែលហ្នឹង បានគេធ្វើសមាហរណ៍កម្មនៅត្រពាំងប្រាសាទនេះ ។

សុវណ្ណៈ ចឹងកាលហ្នឹង ម៉េចបានជាអឹផ្តាច់ខ្លួនចូលមកខាងរដ្ឋាភិបាលមុន?

សឿនៈ ខ្ញុំនឹកឃើញថា ពិបាករត់គេវាយហើយ ខ្ញុំថានៅជាមួយតាម៉ុក គេវាយរត់ទៀតហើយ ពួកភូមិខ្ញុំថា មកគេគ្មានធ្វើបាបអីទេ គាត់មកមានបើកភួយអីឲ្យ គេថាមិនអីទេមក ខ្ញុំមកនៅនេះដែរ ខ្ញុំថាម៉េចៗខ្ញុំទៅហើយ ដល់មកដល់ទំនប់តាម៉ុក នៅអូរស្មាយដែរ ស្រាប់គេថាពួកតាម៉ុក មកហើយ មកដល់២៣គីឡូ ខ្ញុំខ្លាចពួកតាម៉ុក ជម្លៀសខ្ញុំមកទាំងយប់ដើរពីព្រះប្រឡាយមកដល់ទំនប់ដាច់ហ្នឹងខ្លាចពួកតាម៉ុក គៀទៅវិញ ពួកប្តីខ្ញុំថាមិនទៅវិញទេពិបាកណាស់ ស្តាយតែកូនមានអីទេ ពរស្តាយកូនខ្ញុំមីមិញអីនៅតូច វាទើបកើត ខ្ញុំថាពីណាទៅណាទៅ អ្នកត្រពាំងប្រាសាទថា គេមិនបោលតាទេ បើបោលតាផាប់ ។

សុវណ្ណៈ តាណា?

សឿនៈ តាម៉ុក ។

សុវណ្ណៈ តាម៉ុក?

សឿនៈ ចាស!ហ្នឹងអ្នកខ្លះគេមិនចង់មក គេចង់នៅជាមួយតាម៉ុក ខ្ញុំថាមិនទៅទេពិបាករត់ណាស់ តែដល់ក្រោយមកឡើងទៅជាំអីនេះ ទ័ពយើងទាហានយើងវាយមកទាំងអស់ដែរ មុនអ្នកខ្លះគេ

គេចតើ ខ្ញុំថាមិនគេចទេ នឹកឃើញពិបាកដែរ ខ្ញុំស្មាទោសពីដើមម៉ែឪខ្ញុំក្រពីដើមទៅណាក៏មានរទេះគោជិះដែរ នេះស្តាយតែកូនពរពិបាក សួរអ្នកភូមិមើលខ្ញុំទៅណាយំសួរយាយនោះមើល ខ្ញុំមិនសូវប៉ុនស្តាយប៉ុនពរផង ខ្ញុំទៅណាម្តងៗខ្ញុំយំហើយ ប្តីខ្ញុំមិននៅផងខ្ញុំពិបាកមែនទែន តាំងពីកើតពោះម៉ែខ្ញុំមិនដែលពិបាកអីទេ ។

សុវណ្ណៈ ចឹងសម្រាប់ខ្លួនអ៊ីផ្ទាល់ អ៊ីយល់ថាយ៉ាងម៉េចសង្គ្រាម?

សឿនៈ ខ្ញុំនឹកឃើញពីមុន គេចេះតែឃោសនាថា នៅជាមួយតា មកផ្តាច់ខ្លួនខ្លាចគេធ្វើបាបក្មួយឯងមិនដែលចូលឃួនកាប់សម្លាប់ចឹង ចេះតែមិនហ៊ានទៅ ដល់ពេលពួកទ័ពគេចូលផ្តាច់ខ្លួនគេថាមិនអីទេ ។

សុវណ្ណៈ ចឹងសម្រាប់ខ្លួនអ៊ីផ្ទាល់អ៊ីធ្លាប់ឆ្លងកាត់របបសង្គ្រាម របបលន់ នល់ របបខ្មែរក្រហម ខ្លួនអ៊ីផ្ទាល់អ៊ីយល់ឃើញថា សង្គ្រាមវាផ្តល់ផលប្រយោជន៍ឬមិនបានផ្តល់ផលប្រយោជន៍ទេ?

សឿនៈ អត់ទេ ក្មួយលែងជឿហើយព្រោះអី គេថានែកតស៊ូទៅចាំឯករាជ្យ ជួយធ្វើផ្ទះជួយគោជួយពួកខ្ញុំហ្នឹង ដល់វាយចប់មួយសារមុនជំនាន់អ៊ុនតាក់ហ្នឹង ក្មួយមានបានស្អី តែយើងមិនដឹងជាទៅខាងណា បើយើងមិនមានខ្សែរយៈអីដែរ មានដូចយើងឥឡូវមានទូរស័ព្ទគេណាទាក់ទងអ្នកស្រុកអ្នកភូមិណា ទៅស្រុកខ្លាចឃួនអាករ ចេះតែនៅទៅ ។

សុវណ្ណៈ ចឹងអ៊ីយល់ថា សង្គ្រាមវាអាចផ្តល់ផលលំបាកឲ្យប្រជាជនទេ?

សឿនៈ ចាស!លំបាកណាស់ ។

សុវណ្ណៈ លំបាកយ៉ាងម៉េចទៅ?

សឿនៈ លំបាករត់លូនគ្រាប់រំសេវហ្នឹង ពេលរត់ម្តងៗខ្ញុំស្តាយកូនចង់ងាប់ ។

សុវណ្ណៈ ចឹងអ៊ីនើយណាយនិងការរត់គេចគ្រាប់ នើយណាយនិងសង្គ្រាមនើយណាយនិងការបាញ់គ្នាទេ?

សឿនៈ ចាស!ខ្ញុំមិនចង់ជួបប្រទះចង់តែរួចខ្លួន ។

សុវណ្ណៈ ចឹងដល់ពេលកូនចង់ធ្វើទាហានឲ្យទេ?

សឿនៈ កូនខ្ញុំអត់ទេ មានតែកូនប្រសារធ្វើទាហាន ។

សុវណ្ណៈ តែចំពោះអ៊ីផ្ទាល់យល់ឃើញថាយ៉ាងម៉េចសង្គ្រាមហ្នឹង?

សឿនៈ ខ្ញុំយល់សង្គ្រាមពិបាកណាស់ រត់លូនទៅ រត់បណ្តើរគ្រាប់ដេញបណ្តើរនេះខ្ញុំថាមិនចង់ជួបប្រទះទេ ខ្ញុំវេទនាឆ្អែតឆ្អន់អស់ហើយ ។

សុវណ្ណៈ អ៊ីធ្លាប់ឆ្លងកាត់របបខ្មែរក្រហម អ៊ីយល់ឃើញថា បើរបបបីឆ្នាំហ្នឹងជារបបយ៉ាងម៉េច?

សឿនៈ អាហ្នឹងរបបពុករលួយនោះ ។

សុវណ្ណៈ មេ៉ចបានជាថា ពុករលួយ?

សឿនៈ ចុះបើអត់មានវត្តមានវ៉ាំនៅតែព្រៃ គ្មានវត្តគ្មានវ៉ាំ មិនដឹងជាថ្ងៃណាបុណ្យជុំគ្នាទេ នៅតែព្រៃហ្នឹង បើមានបុណ្យ បុណ្យមិន្ទឹង ក្រៅពីមិន្ទឹងមិនដឹងថាមានបុណ្យស្អីទេ របបយើងពីមុននោះ ។

សុវណ្ណៈ អ៊ីយល់ថា របបហ្នឹងឃោរឃៅឬមិនឃោរឃៅពេក?

សឿនៈ ឃោរឃៅណាស់ ។

សុវណ្ណៈ មេ៉ចបានជាអ៊ីថា របបហ្នឹងឃោរឃៅចឹង?

សឿនៈ ឃោរឃៅហើយបើគ្នាហូបបបរអីចឹង តែកង់ខ្ញុំមិនសូវជាលំបាក ខ្លះគេលំបាក អ្នកដែលលំបាកដែលហ្នឹង ម៉ែខ្ញុំអីហូបតែបបរដែលហ្នឹង ខ្ញុំមួយសារនៅកងបាយគ្រប់គ្រាន់ចឹងគេខែវស្សាឡើងបាយលាយពោត បានបាយតែលាយពោត អត់មានបានបាយសុទ្ធទេ ខ្ញុំមិនចេះបាយលាយពោតទេ ពោតៗខ្ញុំរើសចេហអស់ហើយ ។

សុវណ្ណៈ ចឹងអ៊ីថា របបហ្នឹងឃោរឃៅមេ៉ចបានអ៊ីរត់មកតស៊ូជាមួយខាងខ្មែរក្រហមនេះ?

សឿនៈ ចុះបើប្ដីនៅធ្វើទ័ពខ្មែរក្រហមដែរ គេឲ្យមកចេះតែមកៗទាំងគេទាំងខ្ញុំមកទាំងអស់គ្នាមិនថាពីណាពីណីម៉ាស្រុកម៉ាភូមិគេទៅទាំងអស់ហើយ ដឹងទៅណាចេះតែទៅៗ ។

សុវណ្ណៈ ចឹងសម្រាប់អ៊ីផ្ទាល់ អ៊ីគិតថា អ្នកដឹកនាំក្នុងរបបហ្នឹងឃោរឃៅជារបបហ្នឹងឃោរឃៅតែម្ដងពេលហ្នឹង?

សឿនៈ សម្រាប់ខ្លួនខ្ញុំមេខ្ញុំដឹកនាំដូចជាមិនអីដឹង របបគេមកពីលើដឹង គេយល់ខ្ញុំខ្លះដែរ អន្ដភាពគេតាមស្ដាប់ទៅថា របបហ្នឹងតឹងណាស់ វែកអាចម៍វែកដីអីខ្ញុំអត់អីទេ ខ្ញុំថាលោរបបពីលើមកហ្នឹងណាស់ បើមេខ្ញុំហ្នឹង អត់មានឲ្យទៅវែកអាចម៍វែកដីណាទាំងធុងៗអត់ទេ ។

សុវណ្ណៈ ចឹងអ៊ីសព្វថ្ងៃមានដាក់បង្រៀនរឿងរបបខ្មែរក្រហមទៅក្នុងសាលារៀនអ៊ី ឲ្យកូនសិស្សរៀននៅតាមវិទ្យាល័យពីថ្នាក់ទី៩ដល់ថ្នាក់ទី១២ តើអ៊ីយល់ឃើញការរៀនសូត្ររឿងវ៉ាវជាប្រវត្តិសាស្ត្រតាមសាលារៀន អ៊ីគិតថាវ៉ាជារឿងសំខាន់ឬមិនសំខាន់ទេ?

សឿនៈ មានអី សំខាន់ដែលតើ ឲ្យក្មេងវ៉ាដឹង បើកូនខ្ញុំឲ្យតែនិយាយរឿងសង្គ្រាម វ៉ាម៉ែកុំនិយាយរឿងរបបហ្នឹង គេបំបាត់ចោលអស់ហើយ ម៉ែឯងកុំទៅរំលឹក ខ្ញុំតែងនិយាយប្រាប់វ៉ាថាប៉ុណ្ណឹងមានអីលំបាក អញពីដើមលំបាកណាស់ ម៉ែឯងកុំនិយាយរបបហ្នឹងនោះ របបហ្នឹងគេបំបាត់ចោលអស់ហើយ ។

សុវណ្ណៈ ដល់ពេលកូននិយាយចឹង អ៊ីថាយ៉ាងមេ៉ចវិញ?

សឿនៈ ខ្ញុំថា ផែងមិនដឹងអីចេះថា ចឹងឯង ផែងសួរមើលចាស់ៗគ្នាអញហ្នឹង ខ្ញុំថាផែងកើតមកមិន ដឹងចេះតែថាចឹងឯង ។

សុវណ្ណៈ អ៊ំមានដែលនិយាយរឿងជីវិតឆ្លងកាត់ដូចអ៊ំប្រាប់ខ្ញុំថ្ងៃហ្នឹង មានដែលនិយាយប្រាប់លកូន ចៅទេ?

សឿនៈ ប្រាប់ដែលតើ អ្នកស្រុកអ្នកភូមិក៏និយាយប្រាប់កូនខ្ញុំថា ម៉ែផែងពីដើមរត់យំណាស់យាយ មិញហ្នឹងចំណាំតែនិយាយប្រាប់កូនៗខ្ញុំ ដូចជានិយាយលេងចឹងណាក្មួយ ។

សុវណ្ណៈ ចឹងនិយាយប្រាប់ច្រើនតែនិយាយរឿងអីគេប្រាប់?

សឿនៈ និយាយរឿងរត់រឿងលូន សង្គ្រាមសម័យតាម៉ុក ចឹងហើយសម័យកសាងបាយលាយ ពោត សម្លត្រកួនអត់មានអីហូប អញពីដើមសម្លត្រកួនទឹករលីងរលោងចេះតែហូបទៅ ។

សុវណ្ណៈ ចឹងពេលប្រាប់ចឹងទៅកូនថាយ៉ាងម៉េចទៅ?

សឿនៈ កូនវាអត់មានថាអីដែរ វាថាអាហ្នឹងម៉ែឯងទៅគិតអីតាមសម័យហ្នឹងហើយ វាថាចឹងឯង ។

សុវណ្ណៈ ចឹងអ៊ំគិតថា ក្មេងៗគិតថាឲ្យវារៀនឬមួយមិនគួរឲ្យវារៀនទេ ពីរបបខ្មែរក្រហមហ្នឹង?

សឿនៈ ឲ្យវារៀនទៅ ឲ្យវាបានដឹងថា ចាស់ៗយើងពីដើមវាលំបាក ។

សុវណ្ណៈ ចឹងបើចង់ឲ្យរៀន អ៊ំចង់ឲ្យវារៀនរឿងរ៉ាវណា នៅក្នុងរបបខ្មែរក្រហម?

សឿនៈ ឲ្យវារៀនរឿងតស៊ូលំបាក បើអាណាមិនរៀនដឹងរៀនធ្វើអីទេ អារបបយើងចឹង ។

សុវណ្ណៈ ចឹងអ៊ំពល់ថ្ងៃពេញចិត្តការរស់នៅក្នុងពេលបច្ចុប្បន្ននេះទេ?

សឿនៈ ពេញចិត្ត ។

សុវណ្ណៈ ពេញចិត្តយ៉ាងម៉េច?

សឿនៈ អើយ!វាមានផ្សារមានផ្សាត្រឹមត្រូវ វាមានរបបយើងរកស៊ីតាមសេរី យើងធ្វើបាន បានលក់ ខ្ញុំពីដើមដាំដំណាំបានច្រើនមិនដឹងជាយកទៅលក់ណាទេ ។

សុវណ្ណៈ កាលជំនាន់រត់តស៊ូហ្នឹង?

សឿនៈ ចាស!ផ្ទះខ្ញុំចាំសួរអ្នកភូមិអ្នកស្រុកទៅ ខ្ញុំមិនសូវជានៅទំនេរ ។

សុវណ្ណៈ ចឹងមានចំណុចណាដែលយើងមិនពេញចិត្តរស់នៅក្នុងពេលបច្ចុប្បន្ននេះ មានចំណុចណាមិន ពេញចិត្តទេ?

សឿនៈ ខ្ញុំដូចជាមិនមានអីទេ ។

សុវណ្ណៈ អ៊ំគិតថា មានចំណុចណាដែលអ៊ំមិនពេញចិត្ត ត្រង់ចំណុចនេះត្រង់ចំណុចនោះមានទេ?

សឿនៈ ដូចជាមិនមានទេក្មួយ ។

សុវណ្ណៈ ចឹងអ៊ីធ្លាប់ឆ្លងកាត់របបច្រើន មានរបប លន់ នល់ របបខ្មែរក្រហម របបអ៊ីវត់ស្ទ្វ នៅជាមួយខ្មែរក្រហមពីមុនហើយរបបពេលបច្ចុប្បន្ននេះ ក្នុងចំណោមរបបបួនហ្នឹង អ៊ីចូលចិត្តមួយណាជាងគេ?

សឿនៈ ខ្ញុំចូលចិត្តនៅឥឡូវជីង ស្រួលជាង យើងដាំដំណាំបាន ក៏បានលក់ ។

សុវណ្ណៈ ចុះកាលយើងរស់នៅក្នុងរបបខ្មែរក្រហមពីមុននោះវាយ៉ាងម៉េច?

សឿនៈ មុនធ្វើកើតក៏មិនបានលក់ដូរអីបានដែរ ។

សុវណ្ណៈ យើងមានសិទ្ធសេរីភាពយើងមានសិទ្ធដើរហើរទៅណាបានទេ?

សឿនៈ ដើរទៅឆ្ងាយក៏មិនបានដែរ មានបានដើរស្គាល់អ្នកស្រុកអ្នកភូមិណាបាន បានត្រឹមហ្នឹងៗនេះ ឆ្ងាយហើយខ្ញុំត្រឹមទំនប់ដាច់នេះឯងទៅប្រជុំអី ។

សុវណ្ណៈ ចឹងការគោរពប្រត្តិបត្តិសាសនាអីយ៉ាងម៉េចដែរ ទៅវត្តទៅវ៉ាអីបានទេ?

សឿនៈ ទៅវត្តទៅវ៉ាក៏មិនបាន ទៅឆ្ងាយត្រឹមទំនប់ដាច់នេះឯង ។

សុវណ្ណៈ ចឹងឥឡូវយើងមានទៅវត្តទៅវ៉ាបានទេ?

សឿនៈ ឥឡូវទៅវត្តទៅវ៉ា ចង់ទៅស្រុកទៅភូមិ បងប្អូននៅណាណីទៅបានតាមចិត្ត ពីមុនមានដែលបានទៅណា ដឹងថាអ្នកស្រុកភូមិនៅហ្នឹង គ្មានទូរសព្ទ័គ្មានតេអូ គ្មានស្អីទៅបើសុទ្ធតែព្រៃមានផ្លូវណានិងទៅ ខ្ញុំដល់ថ្នាក់នឹកម៉ែខ្ញុំ ខ្ញុំយល់សព្តយើញម៉ែខ្ញុំ ខ្ញុំដឹងខ្លួនឡើងខ្ញុំយំ បងប្អូនដឹងថាធ្វើម៉េចទៅដល់នោះ ។

សុវណ្ណៈ ពេលកាលនៅតស៊ូនេះ?

សឿនៈ ចាស!កាលនៅតស៊ូមិនជឿស្ទួរប្តីខ្ញុំមើល ភ្ញាក់ឡើងខ្ញុំយំហោ ដឹងថាធ្វើមិញទៅដល់វាពិបាកពេកវានឹកទៅ កាលនោះ បើឥឡូវយើងនឹកអី ចង់ទៅៗបើមិនចឹងទូរស័ព្ទទៅលេងទៅអីកាលពីមុននឹកពេកមិនដឹងជាធ្វើយ៉ាងម៉េចទេ កាលខ្ញុំមកប្អូនខ្ញុំនៅតូចៗដល់ពេលឥឡូវមិនដឹងថាធំប៉ុណ្ណា ខ្លាចយើង៧៩នេះ លោយួនចូលស្រុកទៅគេសម្លាប់អស់ក៏មិនដឹង ចេះតែគិតខ្លួនឯង ថាខ្លួនឯងស្រួលហើយខ្លាចប្អូនពិបាក តាមពិតប្អូននោះគេស្រួលជាងយើង ខ្ញុំនឹកឃើញខ្លាចយួនសម្លាប់អស់ចឹង ។

សុវណ្ណៈ ចឹងប្អូនអ៊ីនៅរស់ទាំងអស់ឬមួយមានអ្នកស្លាប់ខ្លះដែរ?

សឿនៈ នៅទាំងអស់គ្នាទេ ។

សុវណ្ណៈ ចឹងសព្វថ្ងៃមានដែលទៅលេងស្រុកកំណើតទេ?

សឿនៈ ទៅតើ ឆ្នាំនេះឡើងបីដង ខែ១នោះម្តង ខែ៣នោះម្តង ខែ៦នោះម្តង ឥឡូវគាត់ស្លាប់បាត់ហើយ ។

សុវណ្ណៈ	អ៊ំទៅលេងស្រុកកំណើតដំបូងនៅពេលណាដែរ?

សឿនៈ	ខ្ញុំទៅឆ្នាំ២០០០ ដំបូងបង្អស់ស្គាល់ប្អូនស្គាល់អីខ្ញុំទៅ។

សុវណ្ណៈ	ចឹងទៅយ៉ាងម៉េចបានស្គាល់ទៅចឹង?

សឿនៈ	ប្អូនខ្ញុំដឹងថាបងឈ្មោះ សឿន ឈ្មោះអីចឹងទៅ។

សុវណ្ណៈ	ចឹងអ៊ំទៅដល់ដំបូងយ៉ាងម៉េច បងប្អូនស្គាល់ព្រោះអ៊ំចេញតាំងពីក្មេងៗដែលដល់ឥឡូវអ៊ំចាស់ដែលហើយ?

សឿនៈ	ខ្ញុំផ្តាច់ខ្លួនដំបូង បងធំនោះគាត់ទៅស្រុក ទៅស្រុកគាត់ប្រាប់ដំណឹងថា ខ្ញុំនៅរស់អីស្រុកភូមិជិតគ្នាហ្នឹង ថាខ្ញុំនៅរស់ចឹងដល់ហើយ ប្អូនខ្ញុំហ្នឹងគេមកលេងម្នាក់ដើរពីស្រែណូយមកនេះដើរមកលេងខ្ញុំហ្នឹងណាស់ បែកបងប្អូនយូរ ប្អូនខ្ញុំអាពៅហ្នឹងដើរមកជាមួយក្នុងភូមិហ្នឹងមកលេងដឹងដំណឹងអី ខ្ញុំឲ្យកូនខ្ញុំទៅមួយឆ្នាំ៩៩ហ្នឹងទៅ។

សុវណ្ណៈ	ចឹងបានន័យថា បងប្អូនអ៊ំមកលេងអ៊ំមុន?

សឿនៈ	ចាស!មកលេងខ្ញុំមុនប្អូនខ្ញុំមុន។

សុវណ្ណៈ	មកឆ្នាំណា?

សឿនៈ	ឆ្នាំ៩៩ហ្នឹងឯង។

សុវណ្ណៈ	ផ្តាច់ភ្លាមៗ?

សឿនៈ	ចាស!ផ្តាច់ខ្លួនបានមួយឆ្នាំដែរ បងកុំភាគាត់ទៅ។

សុវណ្ណៈ	ម៉េចបានដឹងថា អ៊ំនៅនេះ?

សឿនៈ	គេដឹងមកពីបងកុំ គាត់ទៅ គាត់ទៅលេង ដំបូងហ្នឹងមានអ្នកចង់ទៅស្រុកអីចឹងរដ្ឋាភិបាលយើងដឹកយន្តហោះទៅ ឪពុកខ្ញុំទៅស្រុកមិនដឹងជាមានលុយណាទេ កូនចៅច្រើនមិនហ៊ានទៅទេ ដល់ហើយ បងកុំ គាត់ទៅប្រពន្ធកូនគាត់នៅនេះ។

សុវណ្ណៈ	បងកុំ ហ្នឹងពីណាគេ?

សឿនៈ	បងកុំ ឥឡូវគាត់ស្លាប់ហើយ គាត់នៅទួលចារនោះ។

សុវណ្ណៈ	តែគាត់ធ្វើអីគេ កាលពីមុន?

សឿនៈ	កាលពីមុនគាត់ធ្វើទ័ពធ្វើខ្មែរក្រហមដូចគ្នា។

សុវណ្ណៈ	តែពេលផ្តាច់ខ្លួនហើយគាត់ធ្វើអីគេ?

សឿនៈ	ផ្តាច់ខ្លួនហើយគាត់ធ្វើខាង“ក១”ទាហាន គាត់ដឹងដំណឹងគាត់ទៅ គាត់ហ្នឹងដឹងអ្នកភូមិអី ខ្ញុំគាត់ដើរមកវិញ ពីដើមគេដឹកយន្តហោះមក ដឹកអំណោយយកមកឲ្យពួកខ្ញុំហ្នឹង ទៅតាម

រយៈហ្នឹងគាត់មក ពេលប្អូនខ្ញុំមកលេងខ្ញុំឲ្យកូនខ្ញុំទៅមួយ ទៅបានប្រហែលជាមួយខែដឹងបាន មកវិញ ដល់ឆ្នាំ២០០០ បានខ្ញុំទៅ ទៅជាមួយប្រធានភូមិអីនេះឯងទៅលេងស្រុក ។

សុវណ្ណៈ ចឹងមានន័យថាបងប្អូនមកលេងអ៊ីមុន មករកមុន?

សឿនៈ ប្អូនខ្ញុំមកមុន ។

សុវណ្ណៈ ប្អូនទីប៉ុន្មាន?

សឿនៈ ប្អូនពៅបង្អស់ហើយ ។

សុវណ្ណៈ ចឹងមកមុនតាមរយៈយ៉ាងម៉េចកាលហ្នឹង?

សឿនៈ គេមកតាមរយៈដឹងដំណឹងតាមបងភុំហ្នឹង ។

សុវណ្ណៈ ចឹងគេមកតាមបងភុំហ្នឹងទៅ?

សឿនៈ ចាស!ហ្នឹងហើយ ដឹងចឹងថា ខ្ញុំនៅរស់អីចឹងប្អូនខ្ញុំគេមកឲ្យឃើញជាក់ស្តែង ។

សុវណ្ណៈ ស្រីឬប្រុស?

សឿនៈ ប្រុស ដូចថាគេមិនជឿបាត់យូរហើយនោះ ដល់មកឃើញខ្ញុំអីចឹង ។

សុវណ្ណៈ ចឹងស្គាល់គ្នាយ៉ាងម៉េច ប្អូនអ៊ីនិងអ៊ីហ្នឹង?

សឿនៈ ស្គាល់ដឹងថា ខ្ញុំកូនម៉ែខ្ញុំចឹងទៅណា គេថាបងសឿន នៅរស់តើ គាត់នៅជិតខ្ញុំអីខ្ញុំបងភុំ គាត់ប្រាប់ចឹង ចឹងនៅទេក្អួយ បងភុំ ប្រាប់ថានៅតើ ចឹងបងប្អូនខ្ញុំក៏ចង់ជាក់ស្តែងទៅជា មួយសាកមើលទៅ ប្អូនខ្ញុំអាហ្នឹងវាអ្នកដើរដែរ ក៏វាមក មកទៅបានដឹងឃើញចឹងក៏នាំកូនខ្ញុំ ទៅលេងវិញមួយ ។

សុវណ្ណៈ ចឹងពេលជួបគ្នាដំបូងមានអារម្មណ៍យ៉ាងម៉េចអ៊ី?

សឿនៈ មានអារម្មណ៍ម៉េច នឹកយំហ្នឹងវាក៏នឹកឯង ឯងក៏នឹកវា ពេលខ្ញុំទៅស្រុកអីប្អូនខ្ញុំឃើញយំ អោបគ្នា យំដូចជាមនុស្សក្មេង បើមិនដែលបានជួបគ្នា ។

សុវណ្ណៈ អ៊ីយំឬប្អូនយំ?

សឿនៈ ខ្ញុំក៏យំប្អូនខ្ញុំក៏យំ យំទាំងអស់គ្នា ប្អូនខ្ញុំយំស្មានថាខ្ញុំស្លាប់បាត់ហើយ ព្រោះមិនដែលបាន ឃើញដំណឹងសោះ ឮល្បីថានៅជំរំណានោះ ខ្ញុំមិនដែលបាននៅជំរំទេ ។

សុវណ្ណៈ ចឹងកាលហ្នឹង បាត់ដំណឹងចេញពីផ្ទះឆ្នាំណា?

សឿនៈ ខ្ញុំតាំងពីឆ្នាំ៧៧នោះ មិនដែលបានដឹងសោះរហូតមកនៅនេះ ។

សុវណ្ណៈ ចឹងការហើយក៏បាត់ដំណឹងទៅ?

សឿនៈ ចាស!ខ្ញុំមិនបានការ ខ្ញុំមិនបានការ ខ្ញុំមកការនៅនេះមកតាមទ័ព ម៉ែខ្ញុំមានបានការឲ្យណា រហូតទើបឆ្នាំ២០០០នេះហ្នឹង បានខ្ញុំបានទៅជួប ។

សុវណ្ណៈ ចឹងពេលអ៊ីត្រឡប់ទៅផ្ទះយ៉ាងម៉េចដែរ?

សឿនៈ ទៅដល់នឹកបងប្អូននឹកម៉ែ យើងមិនស្គាល់បងប្អូនគ្រាន់ដឹងថា គ្រាន់ដឹងថាបងចេះតែបង មើលម៉ែក៏ចាស់ ប្អូនតូចៗឥឡូវគេបានប្រពន្ធបានកូនគេ ក្មួយខ្ញុំធំៗអស់ហើយ ប្អូនខ្ញុំ យើញខ្ញុំវាយំ ។

សុវណ្ណៈ ចឹងពេលជួបជុំបងប្អូនយើងច្រើននិយាយរឿងអីគេ?

សឿនៈ និយាយរឿងខ្ញុំនៅណាបែកហើយនៅណា ហើយអ្នកភូមិគេមកសួរ ខ្លះបាត់រហូតដល់សព្វ ថ្ងៃទៅ ខ្លះថា សឿន ឯង មានសំណាងណាស់ បានមកជួបម៉ែឪបងប្អូនវិញ ខ្ញុំអត់មាន ផ្លាស់ឈ្មោះអីហ្នឹងគេ ខ្លះគេធ្វើទ័ពចឹងគេផ្លាស់ឈ្មោះ ខ្ញុំមិនដែលផ្លាស់ទេ ខ្លាចបងប្អូនរកមិន យើញ ។

សុវណ្ណៈ អ៊ីអត់មានត្រឡប់ទៅរកស្រុកកំណើតអ៊ីវិញទេ?

សឿនៈ អត់ទេ ប្អូនខ្ញុំបបួលទៅតើ ថាបងឯងមកនៅមក ខ្ញុំឡូស្រែមួយ ខ្ញុំថាខ្ជិលណាស់ស្រុកគេ ឯករាជ្យហើយ បើដូចពីមុនអីអញខ្ជិលរត់ណាស់ អញមកនៅ ឥឡូវគេឈប់វាយហើយ អញមិនមកទេ អញក្រដែរ អញនៅព្រៃ ឯងអ្នកភូមិអ្នកស្រុកមានផ្ទះអីនៅហើយ ខ្ញុំនៅ ខ្ទមតូច ។

សុវណ្ណៈ ចឹងឥឡូវយើងមិនដូរចិត្តទៅនៅជិតបងប្អូននៅស្រុកកំណើតអ៊ីវិញ?

សឿនៈ ខ្ជិលដូរក្មួយ នៅហ្នឹងអត់មានដីធ្លីដែរ នៅនេះទៅមានដីធ្លីឯងនេះហើយ នៅទៅបានធ្វើផ្ទះ ធ្វើសំបែង ។

សុវណ្ណៈ ចឹងយើងកកើតបាននៅនេះហើយ?

សឿនៈ កកើតនេះហើយខ្ជិលទៅ ព្រោះអ្នកស្រុកខ្ញុំវាក្រដីដែលហ្នឹង ក្មួយអើយចង្អៀតដែលហ្នឹង ។

សុវណ្ណៈ អ៊ីភូមិនេះ កាលពីដើមគេហៅភូមិអីគេ ឈ្មោះនៅភូមិនេះ?

សឿនៈ នេះគេហៅតែ៨៩ហ្នឹង ។

សុវណ្ណៈ ឈប់អ៊ី ឥឡូវគេហៅភូមិទួលប្រាសាទ?

សឿនៈ ចាស ។

សុវណ្ណៈ តែពីមុនគេហៅភូមិអីគេ?

សឿនៈ គេហៅតែ“៣៨៩” កងខ្ញុំហ្នឹង ។

សុវណ្ណៈ ចឹងកង៨៩?

សឿនៈ ចាស!ចឹងហើយគេហៅ៨៩ៗ ។

សុវណ្ណៈ ចឹងភូមិ៨៩ពីមុន?

សឿនៈ ចាស! ពួកទំនប់ដាច់នេះ មុនគេហៅភូមិពួក៨៤តើ ។

សុវណ្ណៈ ចឹង៨៩គេហៅយកតាមណា?

សឿនៈ យកតាមកងទាហានហ្នឹង ។

សុវណ្ណៈ កងវរសេនាតូច?

សឿនៈ ចាស ។

សុវណ្ណៈ ហឺ!កងវរសេនាធំ?

សឿនៈ អត់ទេ វរសេនាតូចទេ ខាងខ្ញុំពីមុនមកគេដាក់២៥៩ដល់ពេលហើយចូលជាមួយតាពីន នេះគេដាក់ពួក៨៩ តាពីន គាត់ចូលមកជាមួយតា០៥នេះ ពីមុននៅក្នុងចំណោមកងពល តាសារឿន ដែរ តែវ៉ានៅវះផ្សេងដល់ចឹងមកនៅក្នុងមន្ទីរគាត់នេះតាពីន ហ្នឹងគាត់នៅ គ្រប់គ្រង ។

សុវណ្ណៈ តាពីន ហ្នឹងគ្រប់គ្រងអីគេ?

សឿនៈ គ្រប់គ្រង២៥៩ហ្នឹងឯង ៨៩នេះឯងពួកអ្នកផ្សារឥឡូវហៅពួកខ្ញុំតែ៨៩ ។

សុវណ្ណៈ ពួក៨៩ហ្នឹងគេហៅតាមអីគេ?

សឿនៈ គេហៅតាមទាហានមក ។

សុវណ្ណៈ តែ៨៩ហ្នឹងជាវរសេនាធំឬវរសេនាតូចឬជាកងពល?

សឿនៈ អត់ទេ វរសេនាតូចទេ ពួកកន្លែងតាពីន ហ្នឹងតែមួងមន្ទីរគាត់ហ្នឹង ។

សុវណ្ណៈ ហៅភូមិ៨៩?

សឿនៈ ចាស!ឥឡូវនៅមានអ្នកហៅ៨៩ដែរ ។

សុវណ្ណៈ ចឹងគេចាប់ផ្ដើមកកើតជួឈ្មោះភូមិនៅពេលណាទៅ មកភូមិទួលប្រាសាទវិញ?

សឿនៈ ពេលយើងផ្ដាច់ខ្លួនចូលខាងរដ្ឋាភិបាលនេះឯង ។

សុវណ្ណៈ ចឹងភូមិទួលពង្រគេហៅភូមិអីគេ កាលពីមុន?

សឿនៈ កាលពីមុនដុំភូមិទួលពង្រហ្នឹងគេហៅភូមិ៨៤ គេហៅពួក៨៤តាំងពីទំនប់ដាច់មកដល់នេះ ។

សុវណ្ណៈ ពីទំនប់ដាច់ទៅថ្នល់វិញ?

សឿនៈ ពីថ្នល់មកខាងនេះគេហៅ៨៤ ។

សុវណ្ណៈ ពីថ្នល់ជាតិមកដល់ទំនប់ដាច់?

សឿនៈ ចាស!កាលពីដើម ។

សុវណ្ណៈ ចឹង៨៤ហ្នឹង មានភូមិពង្រ ភូមិសែនសុខ?

សឿន៖ អត់ទេ សែនសុខនេះគេហៅពួក៨៦ ផ្សេងទៀត សែនសុខហ្នឹងកាលពីមុននៅអមអូរខាងនោះគេហៅ៨៦ ។

សុវណ្ណៈ ចឹងទួលពង្រហ្នឹង៨៤?

សឿន៖ ចាស!ជាមួយពួកទំនប់ដាច់ហ្នឹង គេហៅពួក៨៤ ។

សុវណ្ណៈ ចឹងសែនសុខ?

សឿន៖ សែនសុខ គេហៅពួក៨៦ ។

សុវណ្ណៈ ចឹងដល់ពេលភូមិយើងនេះ?

សឿន៖ ភូមិ៨៩ ទួលចារឲ្យនោះគេហៅ"ព៨១" ។

សុវណ្ណៈ ចឹងទួលចារ៨១?

សឿន៖ ចាស!ហើយភូមិជ័យនិវត្តនោះហៅពួក៨៥ អាហ្នឹងហៅយើងតាំងពីតាម៉ុក នោះ ។

សុវណ្ណៈ ហៅតាមវរសេនាតូចទេ?

សឿន៖ ចាស!ហៅយើងតាំងពីតាម៉ុក ដល់ឥឡូវគេដាក់ខាងខ្ញុំហ្នឹងទួលប្រាសាទ សែនសុខ ទួលពង្រ ទំនប់ដាច់ ជ័យនិវត្ត ទួលចារ ។

សុវណ្ណៈ មានភូមិអីទៀត មានប៉ុន្មានភូមិទាំងអស់?

សឿន៖ មាន៦ ។

សុវណ្ណៈ មាន៦ភូមិ?

សឿន៖ ចាស ។

សុវណ្ណៈ សូមម្តងទៀត ដំបូង?

សឿន៖ ហៅភូមិខ្ញុំមុន ទួលប្រាសាទ ។

សុវណ្ណៈ ទួលប្រាសាទពីមុនគេហៅអីគេ?

សឿន៖ គេហៅ៨៩ ។

សុវណ្ណៈ ទី២?

សឿន៖ សែនសុខ ហៅ៨៦ ។

សុវណ្ណៈ ទី៣?

សឿន៖ ទំនប់ដាច់និងទួលពង្រនេះគេហៅ៨៤ ។

សុវណ្ណៈ ទួលពង្រ៨៤?

សឿន៖ ទំនប់ដាច់និងទួលពង្រហ្នឹងភូមិជាប់គ្នាហ្នឹង កាលហ្នឹងគេហៅ៨៤ ដល់ខាងភូមិជ័យនិវត្តគេហៅ៨៥ ដល់ទួលចារគេហៅ៨១ ។

សុវណ្ណៈ	មួយទៀតអីគេ ទើបបាន៥?
សឿនៈ	ចុះទួលពង្រនិងទំនប់ដាច់ជាមួយគ្នា ។
សុវណ្ណៈ	តែនៅខាងទំនប់ដាច់នេះភាគច្រើនតា០៥ជាអ្នកគ្រប់គ្រង?
សឿនៈ	ចាស!ទំនប់ដាច់ហ្នឹងតា០៥តាំងពីយូរមកហើយ គ្រាន់តែកងពលខ្ញុំនៅកងវរសេនាធំផ្សេង មកនៅនេះបានខ្ញុំនៅជាមួយគាត់ ។
សុវណ្ណៈ	ស្រុកត្រពាំងប្រាសាទមានប៉ុន្មានឃុំ?
សឿនៈ	មាន៦ឃុំ ។
សុវណ្ណៈ	មានឃុំទំនប់ដាច់មួយ?
សឿនៈ	មានទំនប់ដាច់ ត្រពាំងប្រាសាទ បាក់អន្លង់ អូរស្វាយ ឃុំផ្អាវ សើច... ។
សុវណ្ណៈ	ចឹងពពែល?
សឿនៈ	ពពែល ខាងអន្លង់វែងទេ ។
សុវណ្ណៈ	ចឹង?
សឿនៈ	អូ!មានព្រះប្រឡាយ ។
សុវណ្ណៈ	ចឹងឃុំព្រះប្រឡាយចូលទៅក្នុងទៀត?
សឿនៈ	នៅតាមនេះ ហួសទំនប់ដាច់បន្តិចទៅដល់ មាន៦ឃុំ ។
សុវណ្ណៈ	ចឹងនៅតាមទំនប់ដាច់នេះគេហៅតាមកងពលឬមានលេខទាហានអីទេ?
សឿនៈ	អត់មានហៅលេខទាហានអីទេ គេដាក់ភូមិយើងបណ្ដោយ ។
សុវណ្ណៈ	ខ្ញុំចង់និយាយពីមុនមក?
សឿនៈ	ពីដើមជំនាន់តាម៉ុក ។
សុវណ្ណៈ	បាទ!គេហៅ?
សឿនៈ	គេហៅតាមទាហានតើ កងវរៈគេ៨១គេហៅ៨១ចឹងទៅ ។
សុវណ្ណៈ	តែនៅក្នុងកងពល៨០១ទេ?
សឿនៈ	ចាស ។
សុវណ្ណៈ	ចឹងនៅក្នុងឃុំផ្សេងៗមានកងពលណាគេគ្រប់គ្រង?
សឿនៈ	មួយឃុំទំនប់ដាច់នេះកងពល៨០១ហ្នឹងឯង ដូចថាបាក់អន្លង់អីអាហ្នឹងតែហៅកងគេផ្សេងទេ ពួក១៧ ។
សុវណ្ណៈ	តែ៨០១គ្រប់គ្រងទាំងអស់?

សឿនៈ	ចាស!តែម៉ាទំនប់ដាច់នេះកងពល៨០១ទេ ខាងបាក់អន្លង់នោះពីមុនមកពួកតាពក គ្រប់គ្រង ។

សុវណ្ណៈ	តាពក កងពលណា កងពលលេខប៉ុន្មាន?

សឿនៈ	មិនបានដឹងថា កងពលលេខប៉ុន្មានទេ ហើយខាងពួកព្រះប្រឡាយនោះ អាហ្នឹងពួកតាហឿនដែរ ។

សុវណ្ណៈ	កងពលណា?

សឿនៈ	មិនដឹងជាកងពលណាទេ កងពល៨០១ដឹងដែរក្មួយ ។

សុវណ្ណៈ	ចឹងសូមម្តងទៀត នៅខាងព្រះប្រឡាយតាហឿន?

សឿនៈ	ចាស ។

សុវណ្ណៈ	តាហឿន មេកងពលគ្រប់គ្រង?

សឿនៈ	ចាស ។

សុវណ្ណៈ	ចឹងមានដឹងថាកងពលណាទេ?

សឿនៈ	អត់ស្គាល់ទេ ។

សុវណ្ណៈ	ខាងតាទំនប់ដាច់នេះតា០៥?

សឿនៈ	ចាស ។

សុវណ្ណៈ	កងពល៨០១?

សឿនៈ	ចាស ។

សុវណ្ណៈ	ចឹងខាងឃុំត្រពាំងប្រាសាទ?

សឿនៈ	ត្រពាំងប្រាសាទជាមួយគ្នាហ្នឹង ។

សុវណ្ណៈ	ចឹងកែ ពក ហ្នឹងនៅគ្រប់គ្រងខាងណា?

សឿនៈ	កែ ពក ហ្នឹងខាង១៧នេះ ពួក១៧បាក់អន្លង់នេះមុនវាមិនមែននៅហ្នឹងណា គេនៅខាងភូមិភាគកណ្តាលទេ ។

សុវណ្ណៈ	ចឹងកាលពីមុននៅស្រុកត្រពាំងប្រាសាទមានប៉ុន្មានកងពលអ៊ីមានដឹងទេ?

សឿនៈ	អត់ដឹង ។

សុវណ្ណៈ	ចឹងមានប៉ុន្មានកន្លែងដែលគេគ្រប់គ្រងខ្លះ មើលនៅទំនប់ដាច់នេះ១ខាងតា០៥?

សឿនៈ	ចាស ។

សុវណ្ណៈ	ព្រះប្រឡាយតាហឿន?

សឿនៈ	ចាស ។

សុវណ្ណៈ	កែ ពក គ្រប់គ្រងនៅណាខ្លះ?

សឿនៈ	កែ ពក ពួក១៧នេះ ពួកត្រពាំងប្រាសាទដែលដឹង ខ្ញុំមិនសូវដឹង ។

សុវណ្ណៈ	ចឹងអឹថាអីគេ?

សឿនៈ	តាពក ហ្នឹងពួកបាក់អន្លង់ណាស់ ឃុំណា ។

សុវណ្ណៈ	ឃុំបាក់អន្លង់?

សឿនៈ	ចាស ។

សុវណ្ណៈ	មានអីទៀតទេ?

សឿនៈ	អត់មានអីទេ ។

សុវណ្ណៈ	ចឹងមានតែបីហ្នឹងទេ?

សឿនៈ	ចាស!ដឹងថាពីណាខ្លះទេ ខ្ញុំវាមិនស្គាល់គេអស់ ។

សុវណ្ណៈ	អឹដឹងច្រើន ខ្ញុំអត់ដឹងបានសួរអឺវិញ?

សឿនៈ	ចាស ។

សុវណ្ណៈ	ខ្ញុំមិនបានដឹងថា ភូមិហ្នឹងគេហៅភូមិ៨៩ផង?

សឿនៈ	ចាស!គ្រាន់ដឹងថា តាពក ហ្នឹងនៅកន្លែងពួក១៧ ពួក១៧ជិតនាំហ្នឹង ឥឡូវគេហៅឃុំបាក់អន្លង់ វាបែកបាក់ខ្លះទៅវាមិនបាននៅជុំទាំងអស់ទេ ហ្នឹងប្រវត្តិពីដើមពួកបាក់អន្លង់ហ្នឹងឯងក្រុមតាពក ។

សុវណ្ណៈ	ចឹងអឹមានដឹងថាគេដាក់ថា ភូមិទួលប្រាសាទ មានមូលហេតុអីបានគេដាក់ទួលប្រាសាទ?

សឿនៈ	ដឹងអត់ដឹងផង គ្រាន់ថា មានទួលមានប្រាសាទនៅហ្នឹងចឹងគេដាក់ទួលប្រាសាទទៅ ។

សុវណ្ណៈ	ពាក្យថា ទួលមានន័យថា យ៉ាងម៉េច ទួលពីមុនមានន័យថាម៉េច មកពីកន្លែងហ្នឹងយ៉ាងម៉េចបានដឹងថាទួល?

សឿនៈ	អត់ដឹងផង មកដល់ហ្នឹងគេដាក់ថាទួលប្រាសាទហ្នឹងគេទៅខ្ញុំមានដឹងអី ។

សុវណ្ណៈ	ចឹងអឹនៅនេះមានប្រាសាទទេ?

សឿនៈ	មានប្រាសាទមួយនៅនេះ ។

សុវណ្ណៈ	ប្រាសាទអីគេ?

សឿនៈ	មានដឹងថាប្រាសាទអឿ គ្រាន់ដឹងថាប្រាសាទៗ ។

សុវណ្ណៈ	នៅឆ្ងាយពីហ្នឹងទៅ ។

សឿនៈ	នោះប្រាសាទនៅត្រង់នោះហ្នឹង នៅជិតផ្ទះខ្ញុំដែរ ។

សុវណ្ណៈ  ចឹងខ្ញុំដូចជារំខានអ៊ំច្រើនហើយ  អ៊ំមានអីចង់បន្ថែមខ្លះទេ  អ៊ីដែលខ្ញុំមិនបានសួរអ៊ំ  អ៊ំមានទេអ៊ំ?

សឿនៈ  ខ្ញុំគ្មានអីទេ ។

សុវណ្ណៈ  អ៊ំមានសំនួរអីចង់សួរខ្ញុំវិញទេ?

សឿនៈ  ចង់សួរដែលតើ  ក្មួយឯងកត់យកទៅណា ។

សុវណ្ណៈ  ខ្ញុំប្រាប់អ៊ំមិញហើយតើ  ចងក្រងជាសៀវភៅមគ្គុទេសស្រុកអន្លង់វែង  សៀវភៅទេសចរណ៍នោះ ។

សឿនៈ  ចាស ។

សុវណ្ណៈ  បើខ្ញុំមិនស្គាល់ប្រវត្តិភូមិហ្នឹង  ពីមុនយ៉ាងម៉េចយ៉ាងម៉ា  ដល់ពេលសរសេរវាអត់ដឹងរឿងដែរ ចឹងទាល់តែយើងច្បាស់  និយាយរួមដូចខ្ញុំអ្នករស់នៅហ្នឹងតែម្តង ។

សឿនៈ  ចាស ។

សុវណ្ណៈ  ខ្ញុំសួរអ៊ំខ្ញុំសរសេរសៀវភៅទៅ  ប្រមូលពត៌មានទៅវាល្អ ។

សឿនៈ  ចាស ។

សុវណ្ណៈ  គេអ្នកសរសេរ ។

សឿនៈ  ចាស ។

សុវណ្ណៈ  ដូចគ្នាចឹង  ព្រោះវាមិនបានស្គាល់ចឹង ។

សឿនៈ  ចាស ។

សុវណ្ណៈ  មានអីចង់សួរខ្ញុំទៀតទេ?

សឿនៈ  ខ្ញុំមិនមានអីទេ  ខ្ញុំសួរតែប៉ុណ្ណឹង ។

សុវណ្ណៈ  ចឹងខ្ញុំអរគុណច្រើន ។

សឿនៈ  ចាស ។

សុវណ្ណៈ  ដែលបានផ្តល់បទសម្ភាសឲ្យខាងខ្ញុំ ។

សឿនៈ  ចាស ។

សុវណ្ណៈ  អរគុណ ។

សឿនៈ  ចាស ។

**ចប់**